## សារពីអ្នកគ្រប់គ្រង (នាយកប្រតិបត្តិ)

របាយការណ៍នេះ បានបង្កើតឡើង និងបង្ហាញពីការអនុវត្តគម្រោងចាប់ពីឆ្នាំ ២០១៧ ដោយក្រុមអ្នកគ្រប់គ្រង និងបុគ្គលិកបច្ចេកទេសរបស់ EPDO ដែលមានទីតាំងនៅភូមិក្បាលហុង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ពោធិ៍សាត់។ រឿងរ៉ាវដែលបានសរសេរនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១៧ ដែលបានបន្លិចផលប៉ះពាល់



នៃកម្មវិធី អង្គការ EPDO ក្នុងការធ្វើការជាមួយប្រជាជននៅតាមជនបទដែលយើងបម្រើ។

នៅក្នុងឯកសារកម្មវិធីអង្គការ EPDO ២០១៧ ការប្រែប្រួលអាកាសធាតុគឺបញ្ជ្រាបល្អិតល្អន់ចូលទៅក្នុងកម្មវិធីរួមមួយនឹងគោលបំណងនៃគម្រោងនិមួយៗផងដែរ។ ផ្តល់សិទ្ធិអំណាចដល់ប្រជាជននៅតាមជនបទដែលរងផលប៉ះពាល់បំផុត ដើម្បីក្លាយជាអ្នកយល់ដឹងកាន់តែខ្លាំងឡើង អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងដើម្បីរកវិធីក្នុងការកាត់បន្ថយហានិភ័យទាំងនោះ។ គំនិតច្នៃប្រឌិតថ្មីមួយទៀតគឺការផ្តោតអារម្មណ៍ ស្តីពីការលើកកម្ពស់ការ ផ្តល់សិទ្ធិអំណាចដល់មេដឹកនាំសំខាន់ៗក្នុងតំបន់រួមមាន គណៈកម្មាធិការអភិវឌ្ឍន៍ (VDCs) និងសហគមន៍ផ្តោតអារម្មណ៍ជាច្រើននៅលើកម្មវិធីអង្គការ EPDO ពីព្រោះយើង មានជំនឿថា មេដឹកនាំក្នុងតំបន់ដែលបានផ្តល់អំណាច នឹងមានគណនេយ្យភាព និងការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព នៃកម្មវិធីនេះ។

ការពង្រឹងសមត្ថភាពដល់ VDCs ភ្នាក់ងារសុខភាពសត្វភូមិ(VAHWs) អ្នកដឹកនាំសំខាន់ៗនៅក្នុងសហគមន៍ បានកើនឡើងបន្តិចម្តងៗ តាមរយៈការអន្តរាគមន៍របស់យើង។ អង្គការ EPDO បានបន្តផ្តល់ការយកចិត្តទុកដាក់ដល់គ្រួសារដែលងាយរងគ្រោះជាក់លាក់បំផុតនៅក្នុងសហគមន៍គោលដៅរួមទាំងស្ត្រីជាមេគ្រួសារ និងប្រជាជនទូទៅនៅក្នុងសហគមន៍ដែលយើងកំពុងបម្រើផងដែរ។

យើងបានផ្លាស់ប្តូរវិធីសាស្ត្ររបស់យើងធ្វើការជាមួយនឹងអ្នកដែលនៅក្នុងភាពងាយរងគ្រោះបំផុត ពីការគាំទ្រចំពោះបុគ្គល ឆ្ពោះទៅរកក្រុមពួកគេនៅក្នុងគោលបំណងដើម្បីគ្របដណ្តប់គ្រួសារជាដៃគូបន្ថែមទៀត។ ជាលទ្ធផលយើងអាចគាំទ្រ បានល្អប្រសើរជាងមុន ដោយភ្ជាប់រវាង VDCs និងអ្នកដឹកនាំសំខាន់ៗនៅក្នុងសហគមន៍ឲ្យពួកគេធ្វើការជាមួយគ្នា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអ្នកដែលងាយរងគ្រោះ។ លទ្ធផលនៃការពង្រឹងសមត្ថភាពដល់ភ្នាក់ងារសុខភាពសត្វភូមិចំនួន ៥៦នាក់ ស្រី០៣នាក់ អ្នកដឹកនាំសំខាន់ៗចំនួន២១៥នាក់ ស្រី១៥០នាក់និងគ្រួសារគោលដៅចំនួន៥៦០ គ្រួសារ។ តាមរយៈការពង្រឹងសមត្ថភាព និងការគាំទ្រនានាបានធ្វើឲ្យពួកគេ មានការផ្លាស់ប្រែទាំងចំណេះដឹង ជំនាញ អាកប្បកិរិយា និងជីវភាពរបស់ ប្រសើរជាងមុន។

ក្នុងនាមអង្គការEPDO និងក្នុងនាមខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណដល់ដៃគូផ្តល់មូលនិធិរបស់យើងដែលបានគាំទ្រ បានធ្វើឱ្យអង្គការ EPDO អាចបម្រើដល់សហគមន៍គោលដៅទទួលបានលទ្ធផលគួរជាទីមោទនៈរហូតមកដល់ពេលនេះ។ វាជាការសំខាន់ដើម្បីចងចាំថា សមិទ្ធផលទាំងនេះ មិនអាចធ្វើបានទេប្រសិនបើគ្មានការគាំទ្រ ពីសំណាក់ភ្នាក់ងារផ្តល់ជំនួយ អង្គការជាតិ អន្តរជាតិ រដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ជាពិសេសដល់ដៃគូអភិវឌ្ឍន៍របស់យើងទាំងអស់រួមទាំងសហគមន៍គោលដៅក្នុងតំបន់ ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការសហការ និងការគាំទ្រល្អ។

ខ្ញុំសូមអរគុណយ៉ាងខ្លាំងដល់មិត្តរួមការងាររបស់ខ្ញុំទាំងអស់សម្រាប់អង្គការ EPDO ដែលមានស្មារតីធ្វើការបម្រើផលប្រយោជន៍ដល់សហគមន៍ដៃគូរបស់យើង ដោយសេចក្តីស្រឡាញ់ ការគោរពវិជ្ជាជីវៈការងារ មានតម្លាភាព គណនេយ្យភាព និងការងារជាក្រុម ដែលបានធ្វើឲ្យមកើតឡើងនូវសមិទ្ធផលទាំងអស់របស់ឆ្នាំ ២០១៧ នេះ ខ្ញុំសូមបញ្ចប់សាររបស់ខ្ញុំតែត្រឹមនេះ។

សង្ឃឹមថា EPDO នឹងទទួលបានការគាំទ្រជាបន្ត ពីអ្នកដែលមានការពាក់ព័ន្ធទាំងអស់ ដែលមិនអាចកាត់ថ្លៃបាន ដើម្បីរួមគ្នាកសាង និងការពារសមិទ្ធផលបច្ចុប្បន្ន និងអនាគត និងដើម្បីបង្កើតវិធីសាស្ត្រប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជារាប់ពាន់នាក់ជួបការលំបាករួមទាំងស្ត្រី និងកុមារដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាល។

## អារម្មណ៏កថា

សមិទ្ធផលទាំងនេះនឹងមិនអាចទៅរួចទេ បើគ្មានការប្តេជ្ញាចិត្តដ៏អស្ចារ្យរបស់ក្រុមប្រឹក្សាភិបាល គណៈ គ្រប់គ្រង សមាជិកបុគ្គលិក និងការគាំទ្រប្រភពថវិកាពីភ្នាក់ងារផ្តល់ជំនួយនានា។

សម្រាប់ឆ្នាំ ២០១៧ សមិទ្ធផលទាំងឡាយត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងធំធេងពីដៃគូផ្តល់ជំនួយដូចជា៖ Australian Catholic Relief / Caritas Australia (ACR/ CA) សហភាពអឺរ៉ុប(EU) តាម រយៈក្រសួងកសិកម្ម និងអង្គការ People in Need (PIN) កម្មវិធី ASPIRE តាមរយៈមន្ទីរកសិកម្មខេត្តពោធិ៍សាត់។

យើងសូមថ្លែងអំណរគុណចំពោះបុគ្គលិកបច្ចេកទេសទាំងអស់ សម្រាប់ការប្រមូលផ្តុំព័ត៌មានពីវិស័យនេះ ហើយដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការងារដ៏លំបាកបំផុតរបស់ពួកគេ និងដៃគូផ្តល់ជំនួយដែលតែងតែគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ EPDO ជាពិសេសដល់អ្នកទទួលផលដែលបានចូលរួមក្នុងកម្មវិធី ដើម្បីកែលំអជីវភាពរស់នៅ និងបច្ចេកវិជ្ជាថ្មី។ សម្លេងរបស់ពួកគេត្រូវបានឮ អ្នកក្រក៏មានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការចូលរួមធ្វើផែនការ ការចូលរួមអនុវត្តគម្រោង និងការចូលរួមតាមដានត្រួតពិនិត្យ និងកែលម្អកម្មវិធីទាំងអស់គ្នា ហើយនេះគឺជាបេសកកម្ម និងគោលដៅរបស់យើង។

ចុងក្រោយយើងសូមថ្លែងអំណរគុណចំពោះ អង្គការដៃគូ ម្ចាស់ជំនួយ ស្ថាប័នរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងប្រជាពលរដ្ឋ សម្រាប់កិច្ចសហការល្អរបស់ពួកគេ និងជោគជ័យដ៏អស្ចារ្យដែលនឹងបន្ត។

## Acronyms and Abbreviations

| | |
|---|---|
| ACR/CA | Australia Catholic Relief/Caritas Austrlia |
| CIP | Commune Investment Plan |
| CAM4SCALE | Civil Society, Authorities and Markets for Sustainable Community Animal Production, Livelihoods and Environment (CAM-4-SCALE) |
| CLTS | Community Led Total Sanitation |
| CSOs | Civil Society Organization |
| EPDO | Environmental Protection and Development Organization |

| | |
|---|---|
| M&E | Monitoring and Evaluation |
| NGO | Non-Governmental Organization |
| NRM | Natural Resource Management |
| OAHP | Office of Animal Health and Production |
| PCDM | Provincial Committee for Disaster Management |
| PIN | People in Need |
| SHG | Self Help Group |
| VAHWs | Village Animal Health Workers |
| VDMG | Village Disaster Management Group |

## ប្រវត្តិអង្គការអភិវឌ្ឍន៍ និង ការពារបរិស្ថាន

អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន EPDOគឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមិនពាក់ព័ន្ធនឹងនយោបាយ ឬគណបក្សណាមួយឡើយ។ អង្គការ EPDO បានបង្កើតឡើងនៅដើមឆ្នាំ១៩៩៨ ដើម្បីធ្វើការទៅលើការការពារបរិស្ថាន ការអភិរក្សអភិវឌ្ឍន៏ធនធានធម្មជាតិ លើកកំពស់នូវជីវភាពប្រចាំថ្ងៃ និងការឆ្លើយតបទៅនឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ។ EPDO បានចុះឈ្មោះ នៅក្រសួងមហាផ្ទៃតាមលិខិតលេខ ៨៩៨សជណ ចុះថ្ងៃ ទី៦ ខែកក្កដាឆ្នាំ ១៩៩៨។

អង្គការEPDOមានបទពិសោធន៍១៩ឆ្នាំក្នុងប្រទេសកម្ពុជាក្នុងការអនុវត្តកម្មវិធី គ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន បន្សាំការប្រែប្រួលអាកាសធាតុ លើកកំពស់នូវជីវរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការបញ្ចូលបច្ចេកវិជ្ជាវិស័យកសិកម្ម (ដំណាំស្រូវ ចិញ្ចឹមសត្វ និងដាំបន្លែ) ទឹកស្អាតអនាម័យ ការអប់រំសិទ្ធិកុមារ និងអភិបាលកិច្ចល្អ។

### ទស្សនះវិស័យ

សង្គមមួយដែលពលរដ្ឋកម្ពុជាគ្រប់រូប រស់នៅដោយមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខមាលភាពល្អប្រសើរ។

### បេសកកម្ម

រួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងការកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា ដែលមានការរស់នៅក្នុងបរិយាកាសល្អ តាមរយៈការកសាងសមត្ថភាព និងពង្រឹងភាពអង់អាចពួកគេ ដើម្បីធ្វើអោយប្រសើរឡើងនូវជំនាញបច្ចេកទេស និងវិជ្ជាជីវៈដែលបង្កើតអោយមានកំណើនប្រាក់ចំណូល។

### គុណតំលៃ

**<u>ការចូលរួម តម្លាភាព ផលប៉ះពាល់ បទពិសោធន៍ក្នុងមូលដ្ឋាន និងចំណេះដឹង</u>**

### ការចូលរួម

គោលការណ៍ការងាររបស់ EPDO ធានាអោយមានការចូលរួមពីអ្នកភូមិនិងអាជ្ញាធរមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងធ្វើអោយប្រសើរឡើងនូវលទ្ធភាព និងការបែងចែកផលប្រយោជន៍

ប្រកបដោយសមធម៌។ បុគ្គលិក EPDO ត្រូវពិគ្រោះជាមួយអ្នកពាក់ព័ន្ធជាច្រើន ក្នុងការរៀបចំ និង ការអនុវត្តកម្មវិធី ដើម្បីជួយធានាថា តម្រូវការរបស់ពួកគេត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធី។

## តម្លាភាព

បុគ្គលិក EPDO ទទួលស្គាល់តម្លៃនៃតម្លាភាពដែលជាប្រតិបត្តិការតាមវិធីសាស្ត្រមួយដែលអនុញ្ញាតឱ្យអ្នកដទៃពិនិត្យមើលថាតើសកម្មភាពអ្វីខ្លះត្រូវបានអនុវត្ត។EPDO ជឿជាក់ថាតម្លាភាពគឺមានសារៈសំខាន់ណាស់សម្រាប់ការផ្តល់កម្មវិធីដែលទទួលបានជោគជ័យ ទាំងការគ្រប់គ្រង និងការអនុវត្ត។

## ផលប៉ះពាល់

EPDO ឲ្យតំលៃលើគណនេយ្យភាព និងការតាមដានការងាររបស់ខ្លួនដើម្បីធានានូវភាពប្រសើរឡើងវិជ្ជមានក្នុងជីវភាពរស់នៅ និងសហគមន៍ដែលយើងធ្វើការជាមួយ។

## បទពិសោធន៍ក្នុងមូលដ្ឋាន និងចំណេះដឹង

បុគ្គលិករបស់ EPDO ត្រូវបានចុះមូលដ្ឋានជាមួយសហគមន៍ដែលពួកគេធ្វើការជាមួយ ហើយនឹងគោរពគ្នា និងបង្កើនចំណេះដឹង និងការអនុវត្តមូលដ្ឋាន។

## គោលដៅ

ដើម្បីលិកកំពស់សិទ្ធអំណាចដល់សហគមន៍ ក្នុងការគ្រប់គ្រងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន និងលើកកម្ពស់គំរូនៃវិស័យកសិកម្ម និងមិនមែនកសិកម្ម ដែលធនទ្រាំនឹងអាកាសធាតុ ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចគ្រួសារ និងសហគមន៍ តាមរយៈការអនុវត្តចម្រុះកម្មសេដ្ឋកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិ។

## គោលបំណងសំខាន់ៗរបស់EPDO

- បង្កើនសមត្ថភាពសមត្ថភាពរបស់អ្នកដឹកនាំអភិវឌ្ឍ ក្នុងការសំរបសំរួលគំនិតផ្តួចផ្តើមរបស់សហគមន៍ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានដោយផ្អែកលើសិទ្ធិជាមូលដ្ឋាន។
- ពង្រីកភាពជាដៃគូនៅថ្នាក់ក្រោមជាតិ និងសហគមន៍ ដោយមានកិច្ចសហប្រតិបត្តិការពេញលេញពីស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីធានាថាការអភិវឌ្ឍន៍សហគមន៍ ដោយផ្អែកលើធនធានជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- កសាងសមត្ថភាពដល់គ្រួសារក្រីក្រ និងគ្រួសារដែលងាយរងគ្រោះអំពីជំនាញ ចំណេះដឹងបច្ចេកទេសក្នុងការប្រកបមុខរបរ និងការធ្វើជំនួញ ដើម្បីធានាថា ការកែលំអជីវភាពរស់នៅ និងកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋប្រកបដោយនិរន្តរភាព។
- កែលម្អបច្ចេកទេស និងបច្ចេកវិជ្ជានៃវិស័យកសិកម្ម ធនទ្រាំនឹងអាកាសធាតុ ថ្លៃប្រឌិតសម្រាប់ផលិតភាពការធ្វើពិពិធកម្ម និងការធ្វើពាណិជ្ជកម្មដើម្បីដោះស្រាយបញ្ហាប្រឈមទីផ្សារ និងកសាងលក្ខខណ្ឌទីផ្សារអំណោយផលក្នុងភាពជាដៃគូពាណិជ្ជកម្ម។

## យុទ្ធសាស្ត្រ

- ពង្រឹងកម្មវិធីដែលរៀបចំឡើងដើម្បីលើកកម្ពស់សន្តិសុខស្បៀងសម្រាប់ទាំងអស់គ្នា
- ស្វែងរកការគាំទ្រដើម្បីឲមានការទទួលស្គាល់សិទ្ធិរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- បង្កើនសមត្ថភាពសហគមន៍ និង រដ្ឋបាលមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ តាមរយៈការពង្រឹងភាពជាដៃគូ និងដំណើរការសង្គ្រោះបន្ទាន់។
- គាំទ្រ និងអប់រំ សកម្មភាពទឹកស្អាត និងអនាម័យសម្រាប់ទាំងអស់គ្នា។
- ពង្រឹងប្រព័ន្ធផ្ទៃក្នុង ដំណើរការ និងការរៀបចំកម្មវិធី។

## ក្រុមគោលដៅ

ដោយផ្អែកលើបេសកកម្មរបស់ខ្លួន EPDO នឹងផ្តល់នូវសកម្មភាពអាទិភាពដល់ប្រជាជនកម្ពុជាដែលរស់នៅក្នុងតំបន់គោលដៅរបស់ខ្លួន ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ឱកាសជីវភាពដែលមាននិរន្តរភាពសម្រាប់ជនក្រីក្រ និងប្រជាពលរដ្ឋទូទៅរួមមាន សមាជិកសហគមន៍ ស្ត្រី យុវជន កុមារ ចាស់ជរា ជនពិការ កុមារកំព្រា និងងាយរងគ្រោះ ក្រុមជួយខ្លួនឯង ភ្នាក់ងារសុខភាពពេទ្យសត្វភូមិ សហគមន៏កសិកម្ម អាជ្ញាធរមូលដ្ឋានភូមិ ឃុំ និងស្រុក ។ រចនាសម្ព័ននៃកម្មវិធីដែលអនុវត្តដោយ EPDO គឺថាបន្ទាប់ពីបញ្ចប់កម្មវិធីនីមួយៗមនុស្សដែលមានគោលដៅអាចរស់នៅប្រកបដោយចីរភាពដោយគ្មានការគាំទ្រពី EPDO ។

ផ្តោតលើវិស័យកម្មវិធី / គម្រោង:

- វិស័យកសិកម្មរួមមាន៖ ដំណាំស្រូវ បន្លែ ការចិញ្ចឹមសត្វ និងការគ្រប់គ្រងធនធានធម្មជាតិ
- ទឹកស្អាត និងអនាម័យ
- គ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

## បុគ្គលិក

បច្ចុប្បន្ន EPDO មានកម្លាំងបុគ្គលិកចំនួន ២០នាក់ (ស្រី១១ នាក់):

| | |
|---|---|
| - នាយកប្រតិបត្តិ | ០១នាក់ |
| - ប្រធានកម្មវិធី | ០១នាក់ |
| - អ្នកសម្របសម្រួលគម្រោង | ០២នាក់ ស្រី១នាក់ |
| - មន្ត្រីរដ្ឋបាលហិរញ្ញវត្ថុ | ០២នាក់ ស្រី១នាក់ |
| - មន្ត្រីគម្រោង | ១៣នាក់ ស្រី៨នាក់ |
| - អ្នកសំអាត | ០១នាក់ ស្រី១នាក់ |

## តើយើងកំពុងធ្វើការជាមួយនរណា នៅកន្លែងណា

### តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង

| ខេត្ត | ស្រុក | ឃុំ | ចំនួនភូមិ | អ្នកចូលរួមក្នុងគម្រោង | | |
|---|---|---|---|---|---|---|
| | | | | គ្រួសារ | មនុស្សសរុប | ស្ត្រី |
| ពោធិ៍សាត់ | កណ្ដៀង | ស្វា | 4 | 455 | 2799 | 1643 |
| | | ស្វាយលួង | 4 | 97 | 461 | 260 |
| | | អន្លង់វិល | 1 | 95 | 470 | 280 |
| | | ស្រែស្ដុក | 7 | 147 | 441 | 305 |
| | | កោះជុំ | 7 | 19 | 72 | 52 |
| | | កញ្ជរ | 7 | 61 | 244 | 180 |
| | | កណ្ដៀង | 4 | 29 | 116 | 81 |
| បាត់ដំបង | មោងឫស្សី | គារ | 3 | 8 | 24 | 16 |
| | | ជ្រៃ | 4 | 34 | 76 | 53 |
| | | តាលាស់ | 8 | 71 | 284 | 198 |
| | | របស់មង្គល | 5 | 83 | 332 | 230 |
| | | មោង | 8 | 92 | 368 | 257 |
| សរុប | | 12 | 62 | 1191 | 5687 | 3555 |

# ១. គម្រោងឆ្នាំ២០១៧

## គម្រោង សន្តិភាព និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព សម្រាប់ទាំងអស់គ្នា

## Peace and Sustainable livelihood for All (PSL)

**គាំទ្រថវិកាដោយ**

## I. ពណ៌នាពីគម្រោង ឬកម្មវិធី

គម្រោងសន្តិភាព និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា បានអនុវត្តនៅក្នុងភូមិគោលដៅចំនួន៦ ភូមិផ្ទះគ ឃុំអន្លង់វិល ភូមិផ្ទះស្រែ ឃុំស្វាយលួង ភូមិក្បាលឈើពុក ធ្លក ព្រៃស្រគុំ និងភូមិវត្តលៀប ឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ តាមការចុះសម្រាបសម្រួល ការតាមដានត្រួតពិនិត្យ និងការសង្កេតផ្ទាល់ បានបង្ហាញថា ភូមិគោលដៅចំនួន៦ ទាំងអ្នកដឹកនាំ និងសមាជិកសហគមន៍បានធ្វើការផ្លាស់ប្តូរមួយចំនួនដូចខាងក្រោម៖

អ្នកដឹកនាំសហគមន៍ មានសាមគ្គីភាព បង្កើតគំនិតផ្តួចផ្តើម ចូលរួមកៀរធនធាន ក្នុងការអភិវឌ្ឍន៍សហគមន៍ មានទំនាក់ទំនងល្អទាំងខាងក្នុងនិងក្រៅសហគមន៍ មានការទទួលខុសត្រូវជាក់លាក់ មានការផ្លាស់ប្តូរការគិត ដោយផ្តោតទៅលើការអភិវឌ្ឍន៍ដែលផ្អែកលើធនធានជាមូលដ្ឋាន ជាជាងការផ្តោតទៅលើបញ្ហា ឬការរង់ចាំទទួលតែជំនួយ។

សមាជិកសហគមន៍ មានការចូលរួមក្នុងដំណើការអភិវឌ្ឍសហគមន៍ ចាប់តាំងពីពេលចាប់ ផ្តើមគម្រោង ការតាមដានត្រួតពិនិត្យ និងឆ្លុះបញ្ចាំងឡើងវិញ។ តាមរយៈការឆ្លុះបញ្ចាំងនេះសមាជិកសហគមន៍ម្នាក់ៗបានចូលរួមត្រួតពិនិត្យនូវលទ្ធផលដែលបានអនុវត្តកន្លងមក ចំណុចដែលធ្វើបានល្អ ចំណុចដែលបានអុវត្តខ្លះ និងចំណុចដែលមិនទាន់បានអនុវត្ត ព្រមទាំងចូលរួមធ្វើផែនការសម្រាប់រយៈពេល៣ខែបន្ត។ ក្នុងដំណើការនេះសមាជិកសហគមន៍បានដឹងអំពីពេលវេលា តួនាទី ការទទួលខុសត្រូវក្នុងការចូលរួមកែលម្អរស្ថានភាពធ្វើឲ្យប្រសើរឡើងដើម្បីសម្រេចការរំពឹងទុករបស់ពួកគាត់។

EPDO បានយកចិត្តទុកដាក់ទៅលើការលើកកំពស់ស្ត្រីឲ្យចូលរួមរាល់សកម្មភាពរបស់គម្រោង ជាពិសេសការជ្រើសអ្នកដឹកនាំ អ្នកសម្របសម្រួលតែងតែផ្តល់ឱកាសអោយស្ត្រីឈរឈ្មោះធ្វើជាអ្នកដឹកនាំក្រុម/សហគមន៍ និងពង្រឹងបន្ថែមអំពីតួនាទី ការទទួលខុសត្រូវ ដើម្បីឲ្យពួកគាត់មានលទ្ធភាពធ្វើការសម្របសម្រួលក្នុងការអប់រំផ្សព្វផ្សាយ អំពីអនាម័យសុខភាព ការត្រៀមបង្ការគ្រោះមហន្តរាយ ធ្វើបទបង្ហាញសម្រាប់ភ្ញៀវទស្សកិច្ចសិក្សា/សិក្ខាសាលាដៃគូរ សម្របសម្រួលកិច្ចប្រជុំក្រុម សម្របសម្រួលដំណើរការ ចុះបញ្ជីរ និងគ្រប់គ្រងបញ្ជីរក្រុមសន្សំ ការចលនាកៀគរការចូលរួម របស់សមាជិកសហគមន៍ ដំណើរការនេះបានលើកទឹកចិត្តសមាជិកសហគមន៍ ជាពិសេសស្ត្រីចូលរួមយ៉ាងសកម្ម និងដោយសេរីនៅក្នុងដំណើរការរៀបចំផែនការ ការអនុវត្ត និងការតាមដាន។

គម្រោងបានគិត និងបញ្ចូលគំនិតយោបល់ ការបញ្ចេញមតិរបស់សមាជិកសហគមន៍រួមមានក្រុមបុរស ស្ត្រី កុមារ ជនពិការ ចាស់ជរា គណៈកម្មការផ្សេងៗ និងអាជ្ញាធរ តាមរយៈការប្រមូលព័ត៌មាន ការកសាងផែនការបញ្ចូលក្នុងផែនការវិនិយោគឃុំ ការសម្រេចចិត្ត ការរៀបចំគម្រោង សរសេរសំណើរ របាយការណ៍ តាមដានត្រួតពិនិត្យគម្រោងរៀងរាល់ត្រីមាស។ ការឆ្លុះបញ្ចាំងគម្រោង៦ខែម្តង អ្នកសម្របសម្រួលបានបែងចែកក្រុមពិភាក្សា ដូចជា ក្រុមបុរស ស្ត្រី កុមារ ចាស់ព្រឹទ្ធាចារ្យ ពួកគាត់សុទ្ធតែបានបញ្ចេញនូវគំនិតយោបល់ល្អៗ ហើយគំនិតទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងលទ្ធផលនៃការឆ្លុះបញ្ចាំង និងការរៀបចំផែនការបន្ត។

នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ អ្វីដែលEPDO បានយកចិត្តទុកដាក់ គឺការពង្រឹងសមត្ថភាពដល់គណៈកម្មការ ដែលមានស្រាប់នៅក្នុងភូមិគោលដៅទៅតាមលទ្ធផលនៃការប៉ាន់ប្រមាណសមត្ថភាពរបស់អ្នកដឹកនាំសហគមន៍ មានដូចជាភាពជាអ្នកដឹកនាំ ការងារជាក្រុម ការប្រាស្រ័យទាក់ទង វិធីសាស្ត្រដោះស្រាយទំនាស់។ល។ ជាពិសេសរំលឹកអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ ក្នុងការសម្របសម្រួល ចាត់ចែង ដឹកនាំ ការកៀគធនធាន ក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន ធ្វើឲ្យប្រជាជនមានទំនុកចិត្ត មានសាមគ្គីភាព និងរួមគ្នាលើកកំពស់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចគ្រួសារ និងសហគមន៍ឲ្យបានកាន់តែប្រសើរឡើង។

**គោលបំណងទី ១៖** ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋចំនួន ៥៤០ គ្រួសារ មនុស្សសរុប ៣៤៤០ នាក់ស្ត្រីចំនួន ១៧៣៣នាក់ តាមរយៈគំនិតផ្តួចផ្តើមប្រកបដោយចីរភាពដែលកសាងស្មារតីសហគមន៍នៅភូមិចំនួន ៦ ឃុំចំនួន៣ នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់។

## II. លទ្ធផលសំរេចបានរបស់គំរោង

### ក្រុមចិញ្ចឹមមាន់:



គម្រោងបានគាំទ្រក្រុមកសិករចិញ្ចឹមមាន់ចំនួន១០២គ្រួសារ ក្នុងនោះ(ភូមិធ្លក១៧គ្រួសារ ព្រៃស្រគុំ១៧គ្រួសារ វត្តលៀប១៧គ្រួសារ ក្បាលឈើពុក១៧គ្រួសារ ភូមិផ្ទះស្រែ១៧គ្រួសារ និងភូមិផ្ទះគរ១៧គ្រួសារ) បន្ទាប់ពីការការចងក្រងក្រុម EPDO បានធ្វើការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ ដូចជា ការសាងសង់ទ្រុងដេក ទ្រុងដើរ ទ្រុងកូន ការធ្វើចំណី ការធ្វើអនាម័យ ការថែទាំ និងវិធានការការពារជម្ងឺសត្វ។ល។ តាមរយៈនៃការចុះតាមដាន និងបង្វឹកបាននង្ហាញថា ក្នុងចំណោមកសិករ១០២គ្រួសារ មាន៧២គ្រួសារស្មើនឹង៧០%បានផ្លាស់ប្តូរពីការចិញ្ចឹមតាមយថាផល មកចិញ្ចឹមមាន់តាមបច្ចេកទេស ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ និង ៣០%ទៀតនៅបន្តអនុវត្តបច្ចេកទេសខ្លះ និងយថាផលខ្លះ។ បច្ចុប្បន្នគ្រួសារដែលចិញ្ចឹមមាន់តាមបច្ចេកទេសបានកាត់បន្ថយនូវអត្រាស្លាប់ និងជម្ងឺមាន់ និងមានការកើនឡើងនូវប្រាក់ចំណូល ក្នុងមួយគ្រួសា



ជាមធ្យមពី២០០,០០០រទៅ៤០០,០០០រក្នុងរយៈពេល៤ខែនៃវដ្តចិញ្ចឹមមាន់។ តាមសំដីបងស្រី ឈិត ឆាន អាយុ៤៥ឆ្នាំ រស់នៅភូមិក្បាលឈើពុក ឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ បាននិយាយថាការចិញ្ចឹមមាន់តាមបច្ចេកទេសបានកាត់បន្ថយនូវជម្ងឺ និងអត្រាស្លាប់របស់មាន់ និងធ្វើឲ្យគ្រួសារខ្ញុំមាន ប្រាក់

ចំណូលពីការចិញ្ចឹមមាន់ ជាមធ្យមពី២៥០.០០០រ ទៅ៣៥០,០០០រក្នុង១វដ្តនៃការចិញ្ចឹមមាន់ ប្រាក់ចំណូលនេះពួកគាត់ប្រើប្រាស់ទៅលើការទិញសម្ភារៈ សម្លៀកបំពាក់សិក្សាកូន ទិញស្បៀងអាហារ សម្រាប់ពង្រីកមុខរបរ និងបំពេញតម្រូវការផ្សេងៗក្នុងគ្រួសារ។

**ក្រុមចិញ្ចឹមជ្រូកៈ**



គម្រោងបានវិនិយោគពូជជ្រូកចំនួន៦០ក្បាល ស្មើនឹង៦០គ្រួសារ ក្នុងនោះ(ភូមិធ្លក ១០គ្រួសារ ព្រៃស្រគុំ១០គ្រួសារ វត្តលៀប១០គ្រួសារ ក្បាលឈើពុក១០គ្រួសារ ឃុំស្បា ភូមិផ្ទះស្រែ១០គ្រួសារ ឃុំស្វាយលួង និងភូមិផ្ទះគរ១០គ្រួសារ ឃុំអន្លង់វិល) គម្រោងបានសហការជាមួយក្រុមហ៊ុនគ្រីនហ្វីត ដើម្បីបង្វឹក និងផ្តល់បច្ចេកទេសដល់គ្រួសារចិញ្ចឹមជ្រូកតាមកិច្ចសន្យាមុននឹងផ្តល់ពូជជ្រូកដល់កសិករ បន្ទាប់ពីផ្តល់ពូជជ្រូកក្រុមហ៊ុនមានតួនាទីក្នុងការចុះតាមដាន ផ្តល់យោបល់ និងបង្វឹកបន្ថែមជាលក្ខណៈក្រុម និងតាមគ្រួសារកសិករដែលទទួលជ្រូក បានចំនួន៦ក្រុម/៦ភូមិ ស្មើ៦០គ្រួសារ។ តាមការត្រួតពិនិត្យតាមដានឃើញថា ពួកគាត់កំពុងអនុវត្តការចិញ្ចឹមតាមបច្ចេកទេសមានទ្រុង ការឲ្យចំណីគ្រប់គ្រាន់ និងការថែទាំបានល្អ។ ក្នុងចំណោម៦០គ្រួសារ មាន១៥គ្រួសារមានប្រាក់ចំណូលពីការលក់ជ្រូកសាច់ និងបានបង្វិលថវិកាចូលក្រុមវិញតាមផែនការដែលបានព្រមព្រៀង ៣០គ្រួសារទទួលបានប្រាក់ចំណូលពីការលក់ជ្រូកសាច់ និងបានយកថវិកានេះទៅពង្រីកការចិញ្ចឹមបន្ថែម មិនទាន់មានលទ្ធភាពបង្វិលចូលក្រុមនៅឡើយ និង១៥គ្រួសារទៀតកំពង់ចិញ្ចឹមជ្រូកមេយកកូនមិនទាន់ទទួលបានប្រាក់ចំណូលនៅឡើយ ដោយកូនជ្រូកមិនទាន់ដល់ពេលដែលត្រូវលក់ចេញ។ EPDOបន្តការយកចិត្តទុកដាក់ក្នុងការចុះពង្រឹង និងតាមដាន និងផ្តល់យោបល់អំពីបច្ចេកទេសចិញ្ចឹមសត្វដល់ពួកគាត់ ឲ្យទទួលបានជោគជ័យក្នុងវិស័យចិញ្ចឹមសត្វ និងការកើនឡើងនូវប្រាក់ចំណូលពីវិស័យសត្វ។

**ក្រុមដាំបន្លែៈ**



គម្រោងបានចងក្រងក្រុមដាំបន្លែបានចំនួន៦ក្រុម មានសមាជិកសរុបចំនួន១៨គ្រួសារ នៅក្នុងភូមិគោលដៅទាំង៦ បន្ទាប់ពីការចងក្រងក្រុមរួចមក EPDO បានបណ្តុះបណ្តាលពីបច្ចេកទេសដាំបន្លែ បានចំនួន១វគ្គទាំង៦ភូមិ ស្មើនឹង១៨គ្រួសារ ក្រោយពីការបណ្តុះបណ្តាល EPDO បានសម្របសម្រួលក្នុងការធ្វើផែនការដាំដុះតាមគ្រួសារ ព្រមទាំងបានវិនិយោគពូជបន្លែ និងសម្ភារៈកសិកម្មមួយចំនួនតាមតម្រូវការគ្រួសារនីមួយៗ។ កសិករទាំង១៨គ្រួសារបានយកបច្ចេកទេសដែលបានផ្តល់ទៅអនុវត្តការដាំដុះរួមមាន បន្លែត្រសក់ សណ្តែកគួ ពោត ស្ពៃ ខាត់ណា។ តាមរយៈការចុះតាមដាន និងបង្វឹកលទ្ធផលបានបង្ហាញថា ពួកគាត់ប្រមូលផលបន្លែបានចំនួនពីរលើករួចមកហើយ លើកទីមួយសមាជិកចំនួន១៤គ្រួសារទទួលបានប្រាក់ចំណូលក្នុងចន្លោះពី៥០០.០០០,០០រ ទៅ៩០០.០០០រ និងសមាជិកចំនួន៤គ្រួសារទៀតទទួលបានប្រាក់ចំណូលពី៩០០.០០០រទៅ១.០០០.០០០រ ការប្រមូលផលលើកទីពីរសមាជិកចំនួន១៨គ្រួសារទទួលបានប្រាក់ចំណូលជាមធ្យមពី៣០០.០០០រ ទៅ



៥០០.០០០រ។ ប្រាក់ចំណូលទាំងនេះពួកគាត់យកទៅបង្កើនមុខរបរធ្វើស្រែ ចូលរួមបដិភាគសាងសង់បង្គន់អនាម័យ សងបំណុលចាស់ ទិញស្បៀងអាហារ មួយចំណែកទិញពូជដាំបន្ត និងផ្គត់ផ្គង់ជីវភាពគ្រួសារប្រសើជាងមុន មិនតែប៉ុណ្ណោះពួកគាត់ពង្រីកសម្ភារៈសម្រាប់បូមទឹកស្រោចដំណាំ បន្លែទៀតផង។ បច្ចុប្បន្នសមាជិកកំពុងបន្តការដាំលើកទីបី រីឯផែនបង្វិលថវិកាត្រឡប់ចូលគម្រោងនៅ រដូវប្រមូលផលលើកទីបី នៅក្នុងខែកក្កដា២០១៧នេះ។ គ្រួសារ

ទាំងនេះពួកគាត់ត្រូវបង្វិលមូលនិធិចូលក្រុម៥០%នៃថវិកាដែលបានវិនិយោគដើម្បីបន្តពង្រីកសមាជិកជាំបន្ថែថ្មី។

## សកម្មភាពជាំដុះស្រូវបង្កើនរដូវ

គម្រោងបានចងក្រងក្រុមធ្វើស្រូវបង្កើនរដូវបានចំនួន៥ក្រុម មានសមាជិកសរុបចំនួន៥០ គ្រួសារ សម្រាប់៥ភូមិ ក្រោយពីការចងក្រងក្រុមរួចមកគម្រោងធ្វើការទំនាក់ទំនងជាមួយមន្ត្រីកសិកម្មស្រុកកណ្តៀង ដើម្បីធ្វើការសម្របសម្រួលវគ្គបណ្តុះបណ្តុះបណ្តាលបច្ចេកទេសដាំស្រូវបង្កើនរដូវ ដល់សមាជិកសហគមន៍៤វគ្គ/ភូមិ មានអ្នកចូលរួមចំនួន៥០នាក់ ៣០នាក់ ក្នុងភូមិចំនួន៥ ក្នុងនោះ (ភូមិព្រៃស្រគុំ១០ ភូមិវត្តលៀប១០ ភូមិធ្លក១០ ក្បាលឈើពុក១០ និងភូមិផ្ទះស្រែ១០នាក់) បង្រៀនទាំងផ្នែកទ្រឹស្តី និងធ្វើបង្ហាញជាក់ស្តែង ពីបច្ចេកទេសវគ្គទី១ ការរៀបចំដី ការជ្រើសរើសពូជ និងវិធីសាស្ត្រអនុវត្តស្រូវបង្កើនរដូវ វគ្គទី២ ប្រើប្រាស់ជី ការដាក់ជីបំប៉ន វិធីសាស្ត្រការថែទាំ វិធានការការពារសត្វល្អិតបំផ្លាញ សត្វល្អិតមានប្រយោជន៍ សត្វល្អិតចង្រៃសិក្សាអំពីស្មៅចង្រៃ វគ្គទី៣ វិធីសាស្ត្រប្រមូលផល និងវគ្គទី៤ ទិវាស្រែបង្ហាញ។





ក្រោយពីបណ្តុះបណ្តាលរួចមក គ្រួសារដែលបានយកបច្ចេកទេសទៅអនុវត្តមានចំនួន៥០គ្រួសារ ក្នុងផ្ទៃដី៥៣ហិចតា (ភូមិព្រៃស្រគុំ១០គ្រួសារផ្ទៃដី១០ហិចតា ភូមិវត្តលៀប១០គ្រួសារ ផ្ទៃដី១០ហិចតា ភូមិធ្លក១០គ្រួសារ ផ្ទៃដី១៥ហិចតា ភូមិក្បាលឈើពុក១០គ្រួសារ ផ្ទៃដី៨ហិចតា និងភូមិផ្ទះស្រែ១០គ្រួសារ ផ្ទៃដី១០ហិចតា) តាមរយៈលទ្ធផលនៃទិវាស្រែបានបង្ហាញថា ទិន្នផលស្រូវតាមទម្លាប់ក្នុង១ហិតាស្មើនឹង២.៨៨០គ.ក្រ ធ្វើស្រូវតាមបច្ចេកទេសក្នុង១ហិតាស្មើនឹង៦.៧២០ ទិន្នផលស្រូវកើន២.៥ដង ទិវានេះផងដែរ កសិករភាគច្រើនមានការចាប់អារម្មណ៏ និងចម្លងបច្ចេកទេសនេះយកទៅអនុវត្តសម្រាប់ការធ្វើស្រែបង្កើនរដូវ ដែលទទួលបានភោគផលជាងស្រូវរដូវវស្សា ។ តាមសំដីលោក យឹម គឹមហ៊ត កសិករនៅភូមិព្រៃស្រគុំបាននិយាយថាខ្ញុំបានធ្វើស្រែតាមបច្ចេកទេស មានការកើនឡើងនូវទិន្នផលស្រូវក្នុងផ្ទៃដី១ហិចតា ចំនួន៦៧០០គ.ក្រ និងទទួលបានប្រាក់ចំណូលពីការលក់ស្រូវ៦លានរៀល នេះបង្ហាញឲ្យឃើញថា មានការកើនឡើងប្រាក់ចំណូលជាងមុន មិនតែប៉ុណ្ណោះខ្ញុំបានចែករំលែកការធ្វើស្រូវតាមបច្ចេកទេសដល់កសិករនៅក្នុងភូមិព្រៃស្រគុំបានចំនួន២១គ្រួសារ បច្ចុប្បន្នពួកគាត់ទាំងនោះបាន និងកំពុងអនុវត្តធ្វើស្រូវតាមបច្ចេកទេសដែលបានចែករំលែក។

## ក្រុមសន្សំដើម្បីផ្លាស់ប្តូរ



អង្គការEPDOបានសម្របសម្រួលបង្កើតក្រុមថ្មីចំនួន៣ក្រុម និងពង្រឹងក្រុមចាស់ចំនួន៤ក្រុម អំពីការចុះបញ្ជីរ ការធ្វើកំណត់ហេតុ ការកំណត់របៀបវារៈប្រជុំ និងរបៀបការគ្រប់គ្រង ដឹកនាំ ជាលទ្ធផលអ្នកដឹកនាំក្រុមមានសមត្ថភាពចុះបញ្ជីខ្ចី សង ដឹកនាំកិច្ចប្រជុំ កំណត់របៀបវារៈប្រជុំ។ល។ តាមរយៈការចុះបង្វឹក និងការតាមដានកន្លងមក សង្កេតឃើញថា ក្រុមដែលបានអនុវត្តល្អចំនួន៤ក្រុម បានអនុវត្តស្របតាមគោលការណ៏ក្រុមសន្សំដើម្បីផ្លាស់ប្តូរ ដូចជាការចូលរួមប្រជុំ ការសន្សំទៀងទាត់ ការកត់ត្រាបញ្ជីស្នាម ការបង្ហាញពីតម្លាភាព ពីប្រាក់សន្សំ ខ្ចី សង និងសមតុល្យសាច់ប្រាក់ដល់សមាជិកនៅក្នុងកិច្ចប្រជុំនិមួយៗ ក្រុមទាំងបីនេះអាច

ជាគម្រូសម្រាប់រៀនសូត្រដល់ក្រុមផ្សេងទៀត។ ដោយឡែក៣ក្រុមផ្សេងទៀត មិនទាន់អនុវត្តបានល្អ ដោយសារទើបបង្កើតថ្មី មិនទាន់មានការយល់ដឹងស៊ីជម្រៅទៅលើផលប្រយោជន៍ក្រុមសន្សំ បានសមស្រប ទៅនឹងលក្ខខណ្ឌនៃក្រុមសន្សំដើម្បីផ្លាស់ប្តូរនៅឡើយ ដែលទាមទារឲ្យមានការចុះតាមដាន និងពង្រឹងបន្ថែម ឲ្យបានញឹកញាប់។ សមាជិកក្រុមចំនួន១០៥គ្រួសារអនុវត្តតាមគោលការណ៍ក្រុមបានល្អ ក្នុងនោះដែរក្នុង ចំណោម១០៥គ្រួសារ មានចំនួន៥៦គ្រួសារបានប្រើប្រាស់ថវិកាក្រុមសន្សំដើម្បីផ្លាស់ប្តូរ ក្នុងការប្រកបមុខ របរមានពង្រីកជំនួញខ្នាតតូច១២គ្រួសារ ពង្រីកការចិញ្ចឹមមាន់៣៦គ្រួសារ ពង្រីកការដាំបន្លែ៨ ពួកគាត់មាន ផែនការបង្វិលថវិកាចូលក្រុមអាស្រ័យទៅតាមមុខរបរ។

**ធនាគារស្រូវ:**



គម្រោងបានធ្វើការពង្រឹងសមត្ថភាពគណៈកម្មការធនាគារស្រូវចំនួន៥ធនាគារ ក្នុងមួយធនាគារស្រូវ២លើក មានគណៈកម្មការចូលរួមចំនួន២៥នាក់ ស្រី៤នាក់ សម្រាប់៥ភូមិក្នុងនោះភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក និងភូមិផ្ទះគរ អំពីការគ្រប់គ្រងបញ្ជីរខ្ចី សង និងស្រូវដែលមានក្នុងជង្រុក។ ក្រោយពីការពង្រឹង សមត្ថភាពរួចមកឃើញថា គណៈការមានសមត្ថភាពក្នុងការចុះបញ្ជីខ្ចី សង រៀបចំផែនការប្រមូលស្រូវ និង ជួសជុល ជង្រុក ចុះប្រមូលស្រូវតាមគ្រួសារ និងផ្សព្វផ្សាយពីការពង្រីកសមាជិកធនាគារស្រូវ ដើម្បីឲ្យ សមាជិកសហគមន៍បានទទួលផលប្រយោជន៍ពីធនាគារស្រូវ មកទល់ពេលនេះធនាគារស្រូវគ្រប់ភូមិបានដំ ណើការស្របទៅតាមគោលការណ៍ លក្ខខន្តិកៈ។

**គោលបំណងទី២៖** ដើម្បីលើកកម្ពស់សុខភាពអនាម័យ និងសុខភាពសហគមន៍ចំនួន ៥៤០ គ្រួសារ មនុស្សសរុប ៣.៤៤០នាក់ ស្ត្រីចំនួន ១.៧៣៣នាក់ តាមរយៈការអប់រំការវិនិយោគលើទឹកស្អាត និងអនាម័ យនៅតាមភូមិចំនួន៦ ឃុំចំនួន៣ នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។

អង្គការEPDOធ្វើការដើម្បីធានាថាសហគមន៍អាចទទួលបានសុខភាពល្អ ដោយផ្តោតទៅលើអនាម័យ និងទឹក ស្អាត។ ប្រជាជនទទួលបានទឹកស្អាត និងការអប់រំពីសារៈសំខាន់ ការអនុវត្តន៍អនាម័យ ជាវិធីចំណាយដ៏មាន ប្រសិទ្ធភាពដើម្បីសម្រេចបានលទ្ធផលពិតប្រាកដសម្រាប់សុខភាព។



តាមរយៈកម្មវិធីអប់រំផ្សព្វផ្សាយ និងការរៀបចំទិវាអនាម័យតាមសហគមន៍ និងសាលារៀន គឺជាផ្នែកមួយ សំខាន់ នៃកម្មវិធីលើកកំពស់អនាម័យជនបទ ទិវាលាងដៃនៅសហគមន៍/សាលារៀន ដែលមានឥទ្ធិពលជំរុញឲ្យសហគមន៍មានការភ្ញាក់រលឹក ចូលរួម លើកកម្ពស់អនាម័យ យល់ពីប្រភពនៃការចម្លងរោគ ព្រមទាំងធ្វើការផ្លាស់ប្តូរ ឥរិយាបទ ដោយធ្វើអនាម័យតាមគ្រួសារជាប្រចាំ ដូចជាសំអាតផ្ទះ ភូមិឋាន ចំណីអាហារ សំលៀកបំពាក់ ពោលគឺអនាម័យនាំមុខដោយសហគមន៍.សកម្មភាពមួយចំនួនដែលជួយជម្រុ ញសហគមន៍ឲ្យមានសុខភាពល្អមានដូចជាៈ

**ទិវាអនាម័យបរិស្ថាន**

គម្រោងបានធ្វើការសហការជាមួយអ្នកស្ម័គ្រចិត្តសុខភាពភូមិក្នុងការប្រមូលសមាជិកសហគមន៍ ដើម្បីពួក គាត់ចូលរួមធ្វើទិវាអនាម័យ បរិស្ថាន បាន១លើកនៅភូមិទាំង៦ និងសាលារៀនចំនួន៤ នៅក្នុងតំបន់គោល ដៅ សមាជិកចូលរួមចំនួន៣០១នាក់ ស្រី១៤០នាក់ សិស្សសាលាចំនួន៨២៦នាក់ ស្រី៤៥៧នាក់ ទិវានេះ



អនុវត្តនៅតាមគ្រួសារចំនួន២៧៣គ្រួសារជាគម្រូសម្រាប់សហគមន៍ និង សាលារៀនចំនួន៤ គឺសាលារៀនទួលតាព្រហ្ម ក្បាលឈើពុក ផ្ទះគរ និង សាលារៀនផ្ទះស្រែ រួចធ្វើការឆ្លុះបញ្ចាំង/ប្រៀបធៀបពីអត្ថប្រយោជន៍នៃការ សម្អាត បរិស្ថានដល់ប្រជាពលរដ្ឋទាំង៦ភូមិ និងកុមារតាមសាលាទាំង៤។ យើងសង្កេតឃើញថា ប្រជាពលរដ្ឋចំនួន១៨០គ្រួសារកំពុងអនុវត្តការបោសសម្អាតបរិស្ថានជុំវិញផ្ទះជាប្រចាំ និង៣០០គ្រួសារទៀតមិនធ្វើជាប្រចាំ ចំពោះគ្រួសារទាំងនេះ បុគ្គលិកសហការជាមួយអ្នកស្ម័គ្រចិត្តសុខភាព ភូមិចុះបង្វឹកតាមគ្រួសារបន្ថែមទៀត ធ្វើយ៉ាងណាអោយពួកគាត់មានការផ្លាស់ប្តូរទម្លាប់ប្រសើជាងមុន ដើម្បី កាត់បន្ថយជម្ងឺផ្សេងៗ។

## កម្មវិធីសហគន៍ដឹកនាំអនុវត្តអនាម័យ(CLTS)



សហគមន៍ដឹកនាំអនុវត្តន៍អនាម័យ គឺជាផ្នែកមួយសំខាន់ នៃកម្មវិធីលើកកំពស់អ នាម័យជនបទ ដែលមានឥទ្ធិពលជំរុញឲ្យសហគមន៍មានការភ្ញាក់រលឹក ចូលរួម លើកកម្ពស់អនាម័យ ជាពិសេសការប្រើប្រាស់ បង្គន់អនាម័យនៅតាមគ្រួសារ ប្រកបដោយនិរន្តភាព។ គ្រប់ការងារទាំងអស់ ដើម្បីសម្រេចបានជោគជ័យ ចាំបាច់ត្រូវតែកំណត់យុទ្ធវិធី ឬជំហានដែលជាឧបករណ៍សម្រាប់ធ្វើសកម្មភាពឲ្យបានច្បាស់លាស់ក្នុងការ ឆ្លើយតបការលើកកម្ពស់កម្មវធីសហគមន៍ដឹកនាំអនុវត្តន៍អនាម័យ CLTS ប្រកបដោយប្រសិទ្ធភាព។ EPDOបានធ្វើការសហការជាមួយគ្រូបង្រៀនតាមសាលារៀន អាជ្ញាធរ និងប្រជាពលរដ្ឋដែលស្ថិតនៅតំបន់ គោលដៅ ចូលរួមកម្មវិធីសហគមន៍ដឹកនាំអនុវត្តអនាម័យ(CLTS)ចំនួន១លើក ៦ភូមិ និង៤សាលារៀន មាន ប្រជាពលរដ្ឋចូលរួមចំនួន៥៨០នាក់ ស្រី៤៦០នាក់ នៅក្នុងភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ផ្ទះ



ស្រែ និងភូមិផ្ទះគរ សិស្សសរុប២៤០នាក់ ស្រី១៣០នាក់។ នៅពេលអ្នកភូមិ បានយល់ដឹងអំពីបញ្ហាទាំងអស់នោះហើយ ពួកគេបានអនុវត្តនូវវិធានការទប់ ស្កាត់ប្រភពចម្លង មានការលាងសម្អាតដៃមុនចាប់កាន់ចំណីអាហារ ក្នុង ចំណោមប្រជាពលរដ្ឋ៥៨០ដែលបានចូលរួម មាន២២៥គ្រួសារនៅក្នុងភូមិ ទាំង៦បានចូលមកចុះឈ្មោះក្នុងបញ្ជីរផែនការសាងសង់បង្គន់អនាម័យតាមគ្រួសារ ព្រមទាំងបានចូលរួមវិនិ យោគថវិកាក្នុងមួយគ្រួសារ៥០ដុល្លារជាមួយអង្គការEPDOសម្រាប់សាងសង់បង្គន់អនាម័យ។

## យុទ្ធនាការអនាម័យសម្រាប់សហគមន៍ និងទិវាលាងដៃសាលារៀន





គម្រោងបានអនុវត្តទិវាលាងដៃក្នុងគោលបំណង បង្កើនចំណេះដឹងព្រមទាំងធ្វើអោយប្រសើរឡើងនូវ សុខភាពអនាម័យសម្រាប់កុមារ និងសមាជិកសហ គមន៍ ទិវានេះធ្វើក្រោយកម្មវិធីCLTSព្រោះដើម្បីឆ្លើយតបនូវការធ្វើឲ្យប្រសើ ឡើងផ្នែកសុខភាពគឺផែនការសាងសង់បង្គន់ និងការលាងដៃដើម្បីកាត់បន្ថយពីប្រភពនៃការចម្លងរោគទាំង៤ មាន រុយ ដៃ បន្លែ និងទឹក គម្រោងអនុវត្ត២លើក នៅសាលាបឋមសិក្សាចំនួន៤ សិស្សចូលរួម១៥៦០នាក់ ស្រី៨៧០នាក់ នៅសហគមន៍អ្នកចូលរួម៧៨០នាក់ ស្រី៣៦០ នាក់ នៅក្នុងភូមិធ្លក ព្រៃស្រគុំ ធ្លក វត្តលៀប ក្បាលឈើពុក ភូមិផ្ទះស្រែ និងភូមិផ្ទះគរ។ ក្រោយពីធ្វើទិវាលាងដៃរួចមកយើងសង្កេតឃើញថាកុមារចំនួន

១០១២នាក់ ស្រីចំនួន៥២៦នាក់ដែលចូលរួមទិវាលាងដៃ និងមនុស្សពេញវ័យចំនួន៤១៦នាក់ ស្រី១៩០ នាក់នៅក្នុងភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ភូមិផ្ទះស្រែ និងភូមិផ្ទះគរ ពួកគាត់មានការផ្លាស់ប្តូរទម្លាប់ ដោយសំអាតអនាម័យទូទៅ និងលាងដៃមុនទទួលទានអាហារបានល្អប្រសើរជាងមុន។

### សកម្មភាពសាងសង់បង្គន់អនាម័យ



ក្រោយពីធ្វើCLTSព្រមទាំងផែនការសាងសង់បង្គន់តាមភូមិនីមួយៗរួចមក អង្គការ EPDOបានធ្វើការឆ្លើយតបការសាងសង់បង្គន់អនាម័យដោយមានការចូលរួមវិនិយោគថវិកាពីសហគមន៍មួយគ្រួសារ៥០ដុល្លារ បង្គន់សាងសង់រួចចំនួន៧៧គ្រួសារ (ភូមិធ្លក ២៦គ្រួសារ ក្បាលឈើពុក៣១គ្រួសារ និងភូមិព្រៃស្រគុំ១២គ្រួសារ វត្តលៀប៣គ្រួសារ ផ្ទះគរ៥គ្រួសារ និងភូមិផ្ទះស្រែ២គ្រួសារ)មកដល់ពេលនេះបង្គន់រួចរាល់ជាស្ថាពរចំនួន៧៧គ្រួសារ ។ ក្រោយពីការសាងសង់បង្គន់រួចមក សមាជិកចំនួន៧៧គ្រួសារមានបង្គន់ប្រើប្រាស់សមរម្យ ជាពិសេសមានបង្គន់សម្រាប់ភ្ញៀវមកចូលរួមកម្មវិធីផ្សេង(បុណ្យ ការកូន)ជាក់ស្តែងតាមសម្តីអ្នកស្រី ផាន ជា ដែលជាសមាជិកភូមិបាននិយាយថាបង្គន់ដែលបានសាងសង់នៅពេលនេះជួយសម្រួលដល់អ្នកភូមិក្នុងការសុំអនុញ្ញាតិច្បាប់ ធ្វើបុណ្យ ការកូនតាមប្រពៃណី ព្រមទាំងមានបង្គន់សម្រាប់ភ្ញៀវ ប្រើប្រាស់បានស្រួលជាងមុន។ បច្ចុប្បន្នតាមរយៈគម្រោងនានារួមទាំងEPDOផងដែរ មានគ្រួសារមួយចំនួនបានវិនិយោគក្នុងការសាងសង់បង្គន់អនាម័យដើម្បីប្រើប្រាស់ក្នុងគ្រួសារ (ភាគរយនៃប្រជាពលរដ្ឋដែលមានបង្គន់ប្រើប្រាស់ ភូមិផ្ទះគរ៤៦% ភូមិផ្ទះស្រែ៨៥% ភូមិព្រៃស្រគុំ៦៨% ភូមិធ្លក៤៨% ភូមិវត្តលៀប៤៧% ភូមិក្បាលឈើពុក២៤%) និងមាន២២៥គ្រួសារ ក្នុងចំណោមភូមិគោលដៅទាំង៦ បានធ្វើផែនការសាងសង់បង្គន់អនាម័យ សម្រាប់ឆ្នាំបន្ទាប់(២០១៧-២០១៨)។

**គោលបំណងទីបី:**ដើម្បីលើកកម្ពស់យន្តការសុវត្ថិភាពសង្គមដោយមាន ៥៤០ គ្រួសារ / ៣.៤៤០ នាក់ ស្ត្រីចំនួន១.៧៣៣នាក់ តាមរយៈការផ្សព្វផ្សាយការកសាងសន្តិភាព និងភាពជាម្ចាស់របស់សហគមន៍នៅភូមិចំនួន៦ ឃុំចំនួន ៣ នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់។

### អប់រំផ្សព្វផ្សាយអំពីការកសាងសន្តិភាព

មុនពេលធ្វើការអប់រំផ្សព្វផ្សាយEPDOបានធ្វើការប៉ាន់ប្រមាណពីអំពើហឹង្សា លទ្ធផលបានបង្ហាញថានៅក្នុងភូមិគោលដៅទាំង៦ មានអំពើហឹង្សាចំនួន១២ករណី (ហូបស្រា១០គ្រួសារ ល្បែងស៊ីសង២គ្រួសារ)។ បន្ទាប់



ពីបានលទ្ធផលEPDO បានផ្សព្វផ្សាយអំពីការកសាងសន្តិភាព ព្រមទាំងដាក់ស្លាកអប់រំអំពើហឹង្សាតាមភូមិចំនួន៦ភូមិ (ភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ផ្ទះស្រែ និងភូមិផ្ទះគរ) អ្នកចូលរួមក្នុងវគ្គផ្សព្វផ្សាយសរុបចំនួន៤២០ នាក់ ស្រី១៥៦នាក់ កុមារ១១០នាក់ ស្រី៥០នាក់ អំពីការកសាងសន្តិភាព ច្បាប់អំពើហឹង្សា និងផលប៉ះពាល់ដោយសារអំពើហឹង្សា ដើម្បីឲ្យសមាជិកគ្រួសារ និងសហគមន៍ចេះមានសាមគ្គីភាព ចេះជួយទុក្ខធុរៈគ្នាក្នុងគ្រាមានអាសន្ន និងការចូលរួមក្នុងកិច្ចការសង្គមផ្សេងៗ។ EPDOក៏បានចុះតាមដាន និងធ្វើការសហការជាមួយអាជ្ញាធរ និងប៉ូលីសប៉ុស្តិ៍ ដើម្បីធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅនៅភូមិគោលដៅទាំង៦ខាងលើ និងចុះតាមគ្រួសារ ដើម្បីធ្វើអប់រំអំពីច្បាប់អំពើហឹង្សា ដើម្បីកាត់បន្ថយនូវការបង្ករមហន្តរាយដល់គ្រួសារ និងសហគមន៍ដល់ពួកគាត់។ ក្រោយពីការសហការជាមួយប៉ូលីស និងការ

ចុះពង្រឹងរបស់បុគ្គលិកតាមគ្រួសារ បានបង្ហាញថាករណីអំពើហឹង្សាបានថយចុះចំនួន៧ករណី ហើយនៅ៥ករណីទៀត អង្គការEPDO នៅបន្តកិច្ចសហការជាមួយគណៈកម្មការ និងសមត្ថកិច្ច ចុះអប់រំបន្ថែមដើម្បីលុបបំបាត់នូវអំពើហឹង្សាទាំងនេះ ។

## ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ព្រៃឈើ

អង្គការEPDOបានធ្វើការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ព្រៃឈើភូមិផ្ទះគរបានចំនួនមួយវគ្គដែលមានអ្នកចូលរួមសរុប៩នាក់ ស្រី៣នាក់ អំពីយន្តការគ្រប់គ្រងសហគមន៍ ការសិក្សាពីបញ្ហាជួបប្រទះ ដំណោះស្រាយ និងការរៀបចំផែនការបន្ត។



ក្រោយពីទទួលបានការពង្រឹងសមត្ថភាពរួចមកគណៈកម្មការបានចុះយាមល្បាត១សប្តាហ៍ម្តង ធ្វើផ្លូវភ្លើងបាន ប្រវែង ៣៦០០ម៉ែត្រ ជុំវិញផ្ទៃដីព្រៃសហគមន៍មានចំនួន៥៦ហិចតា សមាជិកចូលរួមមានចំនួន៥៧នាក់(ក្នុងនោះគណៈកម្មការ៩នាក់ ស្រី៣នាក់) បានធ្វើការប្រជុំសមាជិកសហគមន៍ដំណោះស្រាយឧបសគ្គដែលពួកគាត់ជួបប្រទះ មិនតែប៉ុណ្ណោះពួកគាត់បានចាត់វិធានការការពារ យាមល្បាតព្រៃសហគមន៏ និងសហការជាមួយអាជ្ញាធរឃុំ ស្រុក និងស្ថាប័នរដ្ឋបាលព្រៃឈើ ដោះស្រាយទំនាស់ពាក់ព័ន្ធនឹងការកាប់រានដីព្រៃសហគមន៍ពីសំណាក់ប្រជាពលរដ្ឋ។

## ពង្រឹងសមត្ថភាពដល់គណៈកម្មការអំពីភាពជាអ្នកដឹកនាំ

EPDOបានពង្រឹងសមត្ថភាព ដល់មេដឹកនាំសហគមន៍បានចំនួន២លើក មានអ្នកចូលរួមសរុប៩០នាក់ ស្រី១០នាក់នៅក្នុងភូមិធ្លក ព្រៃស្រគុំ វត្តលៀប ក្បាលឈើពុក ឃុំស្យា ភូមិផ្ទះស្រែ ឃុំស្វាយលួង និងភូមិផ្ទះគរ ឃុំអន្លង់វិល អំពីភាពជាអ្នកដឹកនាំកម្រិតសហគមន៍ ការគ្រប់គ្រង ការងារជាក្រុម និងការដោះស្រាយទំនាស់។ ក្នុងនោះដែរ EPDOបានបំពេញបន្ថែមដើម្បីឲ្យពួកគាត់មានលទ្ធភាពដឹកនាំអនុវត្តឈានទៅសម្រេចគោលដៅ និងក្តីស្រម័យរបស់ពួកគាត់ ក្រោយពីទទួលបាននូវវគ្គបណ្តុះបណ្តាលពួកគាត់មានសមត្ថភាពក្នុងការ



ដឹកនាំ គ្រប់គ្រង ចាត់ចែង ទំនាក់ទំនង ការបង្កើតគំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍន៍ ការចលនាកៀរគរធនធាន ព្រមទាំងសម្របសម្រួល និងដោះស្រាយនូវបញ្ហាកើតមានក្នុងសហគមន៍ តាមរយៈការវិនិយោគរួមគ្នា និងការអភិវឌ្ឍន៍ដោយភាពម្ចាស់ការរបស់ពួកគាត់។ កត្តាដែលEPDO មើលឃើញការផ្លាស់ប្តូរនោះគឺ អ្នកដឹកនាំសហគមន៏និមួយៗ បានយកចំណេះដឹងទៅអនុវត្តជាក់ស្តែងនៅក្នុងតំបន់គោលដៅនិមួយៗមានលទ្ធផលដូចខាងក្រោម៖

នៅភូមិក្បាលឈើពុកគណៈកម្មការធ្វើការកៀរគរថវិកាបានចំនួន៤.៧០០.០០០រៀលដើម្បីសម្រាប់ជួសជុលសាលាឆទានទំហំ៦x៩x៣ មានទីកន្លែងសមរម្យសម្រាប់សហគមន៍ធ្វើកម្មវិធីជួបជុំ ការសមាទានសីលរបស់ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ និងជាទីកន្លែងជួបជុំសមាជិកសហគមន៍ដើម្បីកៀរគរធនធានចូលរួមអភិវឌ្ឍន៏ភូមិ និង កៀរគរធនធានថវិកាបដិភាគបានចំនួន១.៨០០.០០០រ សម្រាប់សាងសង់លូកាត់ប្រឡាយដើម្បីងាយស្រួលក្នុងការឆ្លងកាត់ និងពិភាក្សាជាមួយក្រុមហ៊ុនធ្វើទ្វារទឹក សុំបន្ថែមខ្នងទំនប់ចំនួន០.៤ម៉ែត្រ ដែលក្នុងប្លង់ទទឹង២ម៉ែត្រ ក្រុមហ៊ុនក៏បានព្រមព្រៀងដែរដោយស្នើសុំឲ្យសហគមន៍ជួយ៥០០.០០០រ ដូចនេះ

ខ្ទងលើទ្វារទឹកមានប្រវែងចំនួន២.៤ម៉ែត្រ ធ្វើឲ្យពួកគាត់ងាយស្រួលក្នុងការឆ្លងកាត់ និងដឹកផលិតផលកសិកម្ម តាមគោយន្ត និងមធ្យោបាយផ្សេងទៀត។

គណៈកម្មការមាតាបិតាសិស្សភូមិថ្នះគរ បានទំនាក់ទំនងជាមួយសប្បុរសជនធ្វើការសាងសង់អណ្តូងស្នប់ក្នុងសាលារៀនមួយតម្លៃ១៧០០ដុល្លារ ដើម្បីឆ្លើយតបតម្រូវការទឹកសម្រាប់ប្រើប្រាស់ក្នុងសាលារៀន ក៏ដូចជាប្រជាពលរដ្ឋនៅក្បែរខាងផងដែរ។

## វិនិយោគកញ្ចប់សម្ភារៈកំសាន្តសម្រាប់សិស្សនៅ៤សាលា:



EPDOបានចូលរួមលើកកម្ពស់សុខមាលភាពរបស់កុមារតាមរយៈការវិនិយោគទូរដាក់សៀវភៅសម្រាប់សិស្សអាន និងសម្ភារៈសិក្សា សម្ភារៈកីឡា សម្ភារៈសម្រាប់សិស្សលេង តាមសាលាក្នុងតំបន់គោលដៅចំនួន៤ទូរ និងទោងវិលចំនួន៣ ទោងរំកិលចំនួន៣(នៅសាលាទួលតាព្រហ្ម១ សាលាក្បាលឈើពុក១ សាលាថ្នះគរ១ និងសាលាថ្នះស្រែ១)។

ការវិនិយោគកញ្ចប់ សម្ភារៈ ទូរ ទោង នៅតាមសាលាបឋមទាំង៤ក្នុងភូមិគោលដៅ បានបង្ហាញឲ្យឃើញ



ថាកុមារចំនួន៣៦០នាក់ កុមារីចំនួន១៧០នាក់បានចូលអានសៀវ ភៅក្នុងបន្ទប់ការិយាល័យ មានសៀវភៅរឿងនិទាន ភាសាអង់គ្លេស និងលេងវាយសីទាត់បាល់ លេងទោងវិល ទោងរំកិល ធ្វើឲ្យកុមារទាំងនោះមានកន្លែងកំសាន្តសប្បាយរីករាយពេលសម្រាកពីការសិក្សា។

## គម្រោងគំនិតផ្តួចផ្តើមរបស់សហគមន៍



អង្គការEPDOបានចុះសិក្សាស្ថានភាពពាក់ព័ន្ធនឹងជីវភាពរស់នៅ និងកត្តាប្រឈមនានា តាមរយៈកិច្ចប្រជុំភូមិ ដែលមានការចូលរួមពីមេភូមិភូមិ ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋទូទៅក្នុងភូមិក្បាលឈើពុក ឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ លទ្ធផលបានបង្ហាញថាប្រជាពលរដ្ឋនៅក្នុងភូមិក្បាលឈើពុកនេះ ជួបការលំបាកដូចជាស្បៀងហូបមិនគ្រប់គ្រាន់ ខ្វះទឹកប្រើប្រាស់ និងស្រោចស្រពស្រូវស្រែ និងដំណាំបន្លែ ជារឿយៗគ្រោះធម្មជាតិ ទឹកជំនន់ និងភាពរាំងស្ងួតតែងតែកើតមានជារៀងរាល់ឆ្នាំ ធ្វើអោយខូចផលដំណាំ បន្លែ ស្រូវ និងសត្វចិញ្ចឹមជាដើម។ល។ ទឹកគឺជាតម្រូវការចម្បងរបស់ពួកគាត់សម្រាប់លើកកំពស់



ផលិតកម្មកសិកម្ម ដូចនេះទាំងអ្នកដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ បានផ្តួចផ្តើមក្នុងការសាងសង់ទ្វារទឹក និងប្រឡាយទឹក ដោយពួកគាត់បានស្នើឡើងថា ទ្វារទឹក ប្រឡាយទឹក បានផ្តល់ផលប្រយោជន៍ជាច្រើនសម្រាប់វិស័យកសិកម្មដូចជា ធ្វើស្រែប្រាំង ស្រែបង្កើនរដូវ ស្រោចស្រប់ដាំបន្លែ ដំណាំរួមផ្សំដើម្បីបង្កើនជីវភាពគ្រួសារ និងសម្រាប់តម្រូវការប្រើប្រាស់ទាំងមនុស្ស និងសត្វនៅក្នុងសហគមន៍របស់ពួកគាត់ ។



គម្រោងសាងសង់ទ្វារទឹកចំនួន១កន្លែង ដែលមានទំហំ៩.៥មx២.៥មx៧.៨ម បានឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋចំនួន៤ភូមិ មាន៤៩៥គ្រួសារ និងស្ថា

ប្រឡាយ១ខ្សែ១.០៤០ម៉ែត្រ នៅភូមិក្បាលឈើពុកមនុស្សសរុប២០៤៣នាក់ ស្រី ១០១៦នាក់ សរុបផ្ទៃដី ៩៩៨ហិចតា (នៅភូមិក្បាលឈើពុកមាន៣១៣គ្រួសារ មនុស្សសរុប១៣២៣នាក់ ស្រី៦២៦នាក់ ផ្ទៃដីស្រែសរុប៦០៣ហិចតា ភូមិក្បាលពាម១៧គ្រួសារ មនុស្សសរុប៧០នាក់ ស្រី៤៥នាក់ ផ្ទៃដីស្រែសរុប៤៥ហិចតា ភូមិត្រពាំងថ្ម១០០គ្រួសារ មនុស្សសរុប៤០០នាក់ ស្រី២១៥នាក់ ផ្ទៃដីស្រែសរុប២០០ហិចតា និងភូមិបឹងចក៦៥គ្រួសារមនុស្សសរុប២៥០នាក់ ស្រី១៣០នាក់ ផ្ទៃដីស្រែសរុប១៥០ហិចតា ភូមិទាំងនេះស្ថិតក្នុងឃុំស្វា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។



ក្រោយពីការសាងសង់ទ្វារទឹកខ្នាតតូច១កន្លែង និងប្រឡាយ១ខ្សែ ក្នុងភូមិក្បាលឈើពុក បានជួយដល់ប្រជាពលរដ្ឋចំនួន១៣២៣គ្រួសារ មនុស្ស៣៣៥៣នាក់ ដែលបានទាញយកទឹកមកប្រើប្រាស់ធ្វើស្រែបានចំនួន១៦៨០៣ហិចតា ធ្វើ១ឆ្នាំពីរ ទៅបីដង ទិន្នផលស្រូវជាមធ្យមក្នុង១ហិចតា៣តោន ក្នុងមួយរដូវ ផ្ទៃដីដែលពួកគាត់ទទួលផលពីការដាំពោត ល្ង សណ្ដែកបាយចំនួន៣០ហិចតា មានទឹកសម្រាប់ស្រោចដំណាំ បន្លែ និងប្រើប្រាស់ផ្សេងៗទាំងរដូវប្រាំង វស្សា។

**មេរៀនដែលបានរៀនសូត្រពីគម្រោង**

ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង EPDO បានរៀនសូត្រមួយចំនួន ដែលអាចយកទៅប្រើប្រាស់ក្នុងគម្រោងផ្សេងទៀត និងដើម្បីរៀបចំផែនការសម្រាប់ឆ្នាំ២០១៧-២០១៨មានដូចជាៈ

ការបង្កើនកិច្ចសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ តាមរយៈវិធីសាស្រ្តការអភិវឌ្ឍន៍ផ្អែកលើធនធានសហគមន៍ជាមូលដ្ឋាន (ABCD) ធ្វើឲ្យប្រជាពលរដ្ឋមានការយល់ដឹង និងចូលរួមក្នុងការធ្វើផែនការ ការអនុវត្ត និងការតាមដានទាំងអស់គ្នា ជាពិសេសបានជួយកាត់បន្ថយបន្ទុកការងារអង្គការមួយចំនួន ហើយក៏ជាជំហ៊ាននៃនិរន្តភាពគម្រោង។

ពេទ្យសត្វភូមិនៅភូមិគោលដៅ បានទទួលវគ្គបណ្តុះបណ្តាល បច្ចេកទេស និងជំនាញក្នុងការផ្សព្វផ្សាយអំពីសេវាកម្ម ធ្វើឲ្យពួកគាត់មានជំនាញ មានភាពជឿជាក់លើសមត្ថភាព និងបានចូលរួមរៀបចំផែនការ ការអនុវត្ត និងតាមដាន ពួកគាត់មិនអាចចូលរួមដោះស្រាយនូវបញ្ហាសុខភាពរបស់សត្វក្នុងភូមិ និមួយៗ ព្រមទាំងបានធ្វើការចែករំលែកនូវសេវាទាំងនោះដល់សមាជិកសហគមន៍ និងបានកាត់បន្ថយនូវអត្រាសត្វឈឺ និងស្លាប់ ធ្វើឲ្យកសិករមានការកើនឡើងនូវប្រាក់ចំណូលពីការចិញ្ចឹមសត្វប្រសើរជាងមុន។

ផលិតផលក្នុងសហគមន៍មានតម្លៃទាប គម្រោងបានរៀបចំផែនការសកម្មភាពដូចជា បង្កើតទីកន្លែងលក់ផលិតផលរួមគ្នាតាមសហគមន៍ រើសកសិករចិញ្ចឹមមាន់ និងក្រុមដាំបន្លែគម្រូនៅភូមិគោលដៅទាំង៦ភូមិ ធ្វើទស្សនៈកិច្ចសិក្សា ផ្លាស់ប្តូរបទពិសោធន៍ទៅលើក្រុមចិញ្ចឹមមាន់ និងបន្លែ ទំនាក់ទំនងបណ្តាញទីផ្សារ ប្រមូលពត័មានទាក់ទងទៅនឹងសង្វាក់ផលិតកម្មមាន់ បន្លែ និងវិភាគ ផ្សព្វផ្សាយលទ្ធផលទៅក្រុមកសិករនៅកម្រិតសហគមន៍ ដើម្បីមានលទ្ធភាពចរចារតម្លៃជាមួយឈ្មួញក្នុងការលក់ផលិតផល។

# ករណីសិក្សាទី១
# ក្រុមសន្សំដើម្បីផ្លាស់ប្តូរ



អង្គការEPDOបានចាប់ផ្តើមអនុវត្តសាកល្បងសម្របសម្រួលក្រុមសន្សំដើម្បីផ្លាស់ប្តូរ ក្នុងភូមិផ្ទះគរ គម្រោងនេះបានធ្វើការជាមួយក្រុមសន្សំប្រាក់ សមាជិកសហគមន៍ទូទៅ គណៈកម្មការ និងអ្នកដឹកនាំក្នុងភូមិទាំងអស់ ដើម្បីអោយពួកគាត់ចាប់ផ្តើមប្រើប្រាស់ធនធានដែលមានស្រាប់ក្នុងសហគមន៍។ កន្លងមក ក្រុមសន្សំដែលមានស្រាប់ មានរចនាសម្ព័ន្ធ មានគោលការណ៍លក្ខន្តិកៈ ប៉ុន្តែមិនសូវមានដំណើរការ ធ្វើអោយសមាជិកក្រុមមិនសូវបរិច្ចាកពេលវេលា ធនធាន ថវិកាចូលរួមសន្សំក្នុងក្រុមរបស់ពួកគេបានទៀងទាត់ឡើយ។ ក្នុងអំឡុងដើមឆ្នាំ២០១៧ អង្គការEPDO បានអនុវត្តគម្រោងសាកល្បងនៅភូមិផ្ទះគរ សម្របសម្រួលបង្កើតក្រុមសន្សំដើម្បីផ្លាស់ប្តូរបានចំនួន២ក្រុម មានសមាជិកចំនួន៣៧នាក់ ស្រីចំនួន២៩នាក់ ដំណើរក្រុមសន្សំដើម្បីផ្លាស់ប្តូររួមមាន ការបង្កើតគោលការណ៍ក្រុម ពង្រឹងសមត្ថភាពលើការចុះបញ្ជីរ ការគ្រប់គ្រងសាច់ប្រាក់ និងការសន្សំប្រាក់ប្រចាំសប្តាហ៍។ ជាលទ្ធផល ប្រធានក្រុមសន្សំប្រាក់ដើម្បីផ្លាស់ប្តូរ ដឹកនាំដំណើរការសន្សំជាប្រចាំរៀងរាល់សប្តាហ៍ដើម្បីអភិវឌ្ឍន៍ក្រុម ក៏ដូចជាសហគមន៍ ដោយមានការប្រជុំទៀងទាត់រៀងរាល់១សប្តាហ៍ម្តង មានរបៀបវារៈដូចជា ការដាក់ប្រាក់សន្សំ រាយការណ៍ពីសមតុល្យសាច់ប្រាក់របស់ក្រុម ពិនិត្យសំណើរខ្ចីប្រាក់របស់សមាជិក រាប់សាច់ប្រាក់ក្រុម ពិនិត្យលទ្ធភាព និងសម្រេចចិត្តឲ្យសមាជិកខ្ចី ការសន្សំប្រាក់ចាប់ពី៥.០០០រៀល ដល់២០.០០០រៀល។



ចំណុចពិសេសរបស់ក្រុម មានភាពម្ចាស់ការ សន្សំថវិកាដោយខ្លួនឯង ការបែងចែកថវិកាកំចី ក៏ដូចជាភាគលៀបផ្សេងៗគឺជាការសម្រេចចិត្តរបស់អ្នកដឹកនាំ និងសមាជិកក្រុម ក្នុងអំឡុពេលរបាយការណ៍នេះ ទឹកប្រាក់សន្សំរបស់ក្រុមមានចំនួន ៦,៣៦៤,៦០០រៀល ការប្រាក់២៥៨,៣០០រៀល ថវិកាក្នុងក្រុមសរុប ៦.៦២២.៩០០រ សមាជិកខ្ចី សម្រាប់យកទៅពង្រីកមុខរបរ ៦,៣៥៥,០០០រៀល ថវិកាកិច្ចការសង្គម៧៩,១០០រៀល ថវិកាសល់ក្នុងក្រុម១៨៨.៨០០រៀល។ សមាជិកសហគមន៍គាត់បានប្រើប្រាស់ថវិកាសន្សំនេះសម្រាប់ ពង្រីកមុខរបរដូចជា៖ ជំនួញខ្នាតតូច ដាំបន្លែ និងការចិញ្ចឹមសត្វ តាមរយៈការចុះតាមដាន បង្ហឹកសង្កេតឃើញថា ពួកគាត់មានភាពងាយស្រួល ដោយមានប្រាក់ក្នុងក្រុមអាចដោះស្រាយតម្រូវការបានទាន់ពេល និងទទួលបានប្រាក់ចំណូលពីការប្រកបមុខរបរបានប្រសើរជាងមុន ។



ការកត់សំគាល់ ភាពខុសគ្នារវាងក្រុមចាស់ និងក្រុមសន្សំដើម្បីផ្លាស់ប្តូរគឺ៖

ក្រុមចាស់ មិនបានគោរពគោលការណ៍ក្រុម ប្រជុំមិនបានទៀងទាត់ ការសន្សំ ខ្ចីសង មិនមានដំណើការ រង់ចាំតែការគាំទ្រថវិកាពីខាងក្រៅ។

ក្រុមសន្សំដើម្បីផ្លាស់ប្តូរ មានភាពសកម្ម ទាំងសមាជិក និងអ្នកដឹកនាំ មានកិច្ចប្រជុំទៀងទាត់ មានរបៀបវារៈច្បាស់លាស់ សមាជិកម្នាក់ៗបានគោរពគោលការណ៍ក្រុម មានភាពជាម្ចាស់ក្នុងការសន្សំ ខ្ចី សង បន្ថយភាពពឹងផ្អែកជំនួយពីខាងក្រៅ។ ការសាកល្បង២ក្រុមកន្លងមក ទទួលបានជោគជ័យគួរឲ្យកត់សម្គាល់ និងអាចរៀនសូត្រយកទៅអនុវត្តនៅក្រុម និងភូមិគោលដៅផ្សេងទៀតបាន។

## ករណីសិក្សាទី២
## ការផ្លាស់ប្តូររបស់គ្រួសារ ស៊ិន ធឿន











លោក ស៊ិន ធឿន ភេទប្រុសអាយុ៣៨ឆ្នាំ ប្រពន្ធឈ្មោះប៉ែន សាវន ភេទស្រី អាយុ៣៥ឆ្នាំ មានសមាជិកសរុប ៥នាក់ស្រី២នាក់ ក្នុងនោះកូនប្រុស២នាក់ និងម្តាយចាស់១នាក់ រស់នៅភូមិធ្លក ឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ភូមិនេះនៅរដូវវស្សារងគ្រោះដោយសារទឹកជំនន់ ធ្វើឲ្យប៉ះពាល់ដល់បន្លែ ដំណាំ ស្រូវរលួយខូចខាត គោក្របីឈឺស្លាប់មួយចំនួនដោយរោគរាតត្បាត ការខ្វះស្មៅ មាន់ទាអណ្តែតទឹកស្លាប់មួយចំនួន ដោយឡែកនៅរដូវប្រាំងវិញ ខ្សត់ទឹកប្រើប្រាស់ ពួកគាត់ដាំដំណាំបន្លែតាមទម្លាប់ ជួបប្រទះនូវឧបសគ្គមួយចំនួនដូចជា សត្វល្អិតបំផ្លាញ រលួយ ទទួលបានទិន្នផលទាប ពេលខ្លះស្ទើរពុំបានពូជវិញ។ តាមសម្តីបងស្រី សាវន ជាប្រពន្ធបានរៀបរាប់ប្រាប់ថា មុនពេលចូលក្នុងគម្រោងខ្ញុំមានជីវភាពលំបាក មានមុខរបរធ្វើស្រែតិចតួច ស៊ីឈ្នួលដកស្ទូង ដកម្អមបេះត្រសាំង អំពិលយកទៅលក់នៅទីផ្សារក្នុងស្រុក ប្តីខ្ញុំធ្វើកម្មករសំណង់ ដែលទទួលបានកម្រៃទាបបំផុត មិនអាចបំពេញការចំណាយប្រចាំថ្ងៃបាន ប្រាក់ចំណូលបានមួយថ្ងៃសម្រាប់តែស្បៀងអាហារមួយថ្ងៃ ពេលសមាជិកគ្រួសារមានជម្ងឺគ្មានថវិកាសម្រាប់ព្យាបាល ខ្ញុំបានដាក់បញ្ចាំដីស្រែដែលមានការប្រាក់ខ្ពស់ដើម្បីយកថវិកាមកធ្វើការព្យាបាលជម្ងឺ មិនតែប៉ុណ្ណោះកូនៗទាំងពីរមិនបានរៀនសូត្រទៀងទាត់ឡើយ រីឯការដាំបន្លែគឺដាំតាមទម្លាប់បានត្រឹមហូបក្នុងគ្រួសារតែប៉ុណ្ណោះ មិនទទួលបានប្រាក់ចំណូលឡើយ។ នៅខែកក្កដា ឆ្នាំ២០១៦ គ្រួសារខ្ញុំបានចូលជាសមាជិកក្រុមដាំបន្លែខ្នាតមធ្យម ខ្ញុំទទួលបានវគ្គបណ្តុះបណ្តាល និងការបង្វឹកអំពីបច្ចេកទេសដាំបន្លែ ដូចជា៖ ការធ្វើដី ការសាបកូន របៀបលើកថ្នាលដាំ ការប្រើប្រាស់ជី ការធ្វើជីកំប៉ុស ការប្រើប្រាស់ថ្នាំកសិកម្ម និងការពង្រឹងសមត្ថភាពអំពីការចុះបញ្ជីក្រុម និងទទួលបានការវិនិយោគគ្រាប់ពូជបន្លែ ព្រមទាំងសម្ភារៈកសិកម្មមួយចំនួនរបស់គម្រោង។ ក្រោយពីទទួលបានចំណេះដឹង និងការបង្វឹកពីគម្រោង ខ្ញុំបានអនុវត្តការដាំដុះតាមបច្ចេកទេសមានដូចជា ត្រសក់ សណ្តែកគួរ ពោត ននោង ហើយប្រមូលផលបន្លែបានចំនួនពីរលើករួចមកហើយ លើកទីមួយទទួលបានប្រាក់ចំណូល ១,៧០០,០០០រៀល លើកទីពីរ ទទួលបាន៥០០,០០០រៀល ប្រាក់ចំណូលទាំងនេះខ្ញុំប្រើប្រាស់ទៅលើការសងបំណុល៣០០.០០០រៀល លោះដីស្រែ ៥០០.០០០រៀល ជួលត្រាក់ទរ័ភ្ជួរដីស្រែ ៣០០.០០០រ ចូលរួមបដិភាគសាងសង់បង្គន់ ២០០.០០០រ ចូលប្រាក់សន្សំប្រចាំសប្តាហ៍២០.០០០រ និងចំណាយសម្រាប់ទិញស្បៀងអាហារ ទិញពូជបន្លែសម្រាប់ដាំបន្ត ទិញសម្ភារៈសម្រាប់បូមទឹកស្រោចស្រប់ដំណាំ និងសម្រាប់ចំណាយផ្សេងៗក្នុងគ្រួសារ បច្ចុប្បន្ននេះគ្រួសារខ្ញុំកំពុងបន្តការដាំលើកទីបីមានសណ្តែកកួរ ត្រសក់ ននោង ខ្ញុំមានផែនការបង្វិលថវិកាចូលក្នុងក្រុមវិញនៅពេលប្រមូលផលលើកទីបី។



គាត់បាននិយាយប្រាប់យើងថា គាត់មានការសប្បាយរីករាយព្រមទាំងពេញចិត្ត ព្រោះគម្រោង បានជួយឲ្យគ្រួសារមានចំណេះដឹង បច្ចេកទេសក្នុងការដាំបន្លែ ដែលធ្វើឲ្យគ្រួសារគាត់មានការផ្លាស់ប្តូរទាំងជីវភាពរស់នៅ ឥរិយាបថ ក្នុងការរប្រាក់ចំណូល និងចេះកែច្នៃដីដែលធ្លាប់ដាក់ចោល មកប្រើប្រាស់អស់លទ្ធភាពទទួលបានប្រាក់ចំណូលសមរម្យ

មានថវិកាបំពេញតម្រូវការក្នុងគ្រួសារ ជាពិសេសកូនទាំងពីរបានចូលរៀនឡើងវិញ ទន្ទឹមនឹងនោះ គ្រួសារខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការEPDO និងម្ចាស់ជំនួយ ACR/ Caritas Australia ដែលបានជួយបណ្ដុះគំនិត ផ្ដល់បច្ចេកទេស និងវិនយោគថវិកាសម្រាប់បង្កើនមុខរបរ ធ្វើឲ្យគ្រួសារខ្ញុំមានការផ្លាស់ប្តូរ រីកចម្រើនគួជាទីពេញចិត្ត។

## ករណីសិក្សាទី៣
## ការផ្លាស់ប្ដូររបស់គ្រួសារ ទិត វ៉ិត

លោក ទិត វ៉ិត អាយុ៣៧ឆ្នាំនិងប្រព័ន្ធ ឈ្មោះ ស្ងួន គឹមឆាយ អាយុ៤១ឆ្នាំ បន្ទុកគ្រួសារសរុបចំនួន៦នាក់ ស្រី ៤នាក់ រស់នៅភូមិផ្ទះស្រែ ដែលជាភូមិនៅតំបន់ដាច់ស្រយាលក្នុងឃុំស្វាយលួង ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។







តាមសម្ដីលោក ទិត វ៉ិត បានរៀបរាប់ប្រាប់ថា ការរស់នៅរបស់សមាជិកសហគមន៍ទាំងអស់ក្នុងភូមិផ្ទះស្រែ មិនខុសពីគ្រួសារខ្ញុំនៅរដូវវស្សារងគ្រោះដោយសារទឹកជំនន់លិចទាំងអស់ក្នុងភូមិ ធ្វើឲ្យដាច់ផ្លូវជាច្រើនកន្លែង ប៉ះពាល់ដល់ការធ្វើដំណើរ បន្លែ ដំណាំ ស្រូវរលួយខូចខាត មានជម្ងឺសត្វរាតត្បាត ដោយឡែកនៅរដូវប្រាំងវិញក្តៅហួតហែង ខ្សត់ទឹកប្រើប្រាស់ គ្មានប្រពន្ធ័ប្រឡាយមេសម្រាប់ចែកចាយទឹក ដែលធ្វើឲ្យបន្លែក្រៀមស្វិត ទទួលបានផលទាប មិនមានទឹកសម្រាប់ធ្វើស្រូវបង្កើនរដូវ ស្វិតទទួលនូវទិន្នផលតិចតួច ពេលខ្លះស្ទើរពុំបានពូជវិញ រីឯផលិតផលដែលសហគមន៍ផលិតបានដូចជាបន្លែ ផ្លែឈើ ត្រី លក់នៅក្នុងភូមិដែលមានតម្លៃទាប ។

ចំណែកគ្រួសារខ្ញុំវិញ មុនពេលចូលក្នុងគម្រោង ខ្វះចំណេះដឹង ជំនាញក្នុងការប្រកបមុខរបរ មានប្រាក់ចំណូលទាប ជំពាក់បំណុលខាងឥណទាន គ្មានថវិកាសម្រាប់បំពេញតម្រូវការ ធ្វើស្រែបន្តិចបន្តួចទទួលបានទិន្នផលទាប សល់ពេលវេលាពីធ្វើស្រែផ្ទាល់ខ្លួន ពួកខ្ញុំបានស៊ីឈ្នួលច្រូតដកស្ទូង ដើម្បីបានថវិកាបន្ថែមមកបំពេញតម្រូវការផ្សេងក្នុងគ្រួសារ ខ្ញុំ និងប្ដីខ្ញុំបង្កើតមុខរបរលក់នំកញ្ចប់ក្មេងៗ និងគ្រឿងទេសតិចតួចតាមលទ្ធភាពដែលគ្រួសារខ្ញុំអាចធ្វើទៅបាន ការលក់របស់ខ្ញុំបែបនេះមានរយៈពេលបីឆ្នាំកន្លងមកហើយ តែទទួលបានប្រាក់ចំណូលទាបមិនអាចដោះស្រាយជីវភាពក្នុងគ្រួសារបានធូរធាឡើយ ។



ដើមឆ្នាំ២០១៧ គ្រួសារខ្ញុំបានចូលជាសមាជិកក្រុមប្រមូលទិញលក់ផលិតផលក្នុងសហគមន៍ តាមរយៈការប្រជុំផ្សព្វផ្សាយពីគម្រោងទូទៅក្នុងភូមិ ដោយមានការជ្រើសរើសរកអ្នកស្ម័គ្រចិត្តប្រកបមុខរបរប្រមូលទិញ លក់ផលិតផលក្នុងភូមិ ដោយលក្ខ័ណ្ឌគឺ (មានមធ្យោបាយអាចដឹកជញ្ជូនផលិតផលកសិកម្មសហគមន៍យកទៅលក់នៅទីផ្សារ និងពីទីផ្សារមកសហគមន៍វិញ មានដើមទុនចូលរួមវិនិយោគសម្រាប់មុខរបរនេះ)។ គ្រួសារខ្ញុំតាំងចិត្ត និងរៀបចំផែនការប្រមូលទិញផលិតផលពីសហគមន៍ខ្ញុំក្នុងតម្លៃសមរម្យ ដែលអាចទទួលយកបានរវាងអ្នកទិញ និងអ្នកលក់ ខ្ញុំទទួលបាននូវការបង្ហាត់បង្ហាញអំពីរបៀបនៃការកាត់ត្រាចំណូលចំណាយ ការណែនាំពីវិធីសាស្រ្ត ប្រមូលទិញ លក់ និងទទួលបានការវិនិយោគទុនចំនួន៣០០ដុល្លារសម្រាប់ពង្រីកមុខរបរ។ ក្រោយពីបានទទួលទុវិនិយោគ ខ្ញុំចាប់ផ្ដើមប្រមូលទិញលក់ផលិតផលក្នុងសហគមន៍ មានបន្លែ ត្រី សាច់ មាន់ ទា យកទៅលក់នៅទីផ្សារ និងទិញទំនិញពីទីផ្សារមកលក់នៅសហគមន៏មានដូចជា ប្រេងសាំង ភេសជ្ជៈ នំចម្រុះ និងគ្រឿងទេស។ល។ ប្រាក់

ចំណូលទទួលបានពីការទិញលក់ជាមធ្យមសម្រាប់ថ្ងៃធម្មតាក្នុងមួយថ្ងៃក្នុងចន្លោះ ពី៥០០.០០០៛ ទៅ ៧០០.០០០៛ និងនៅពេលរដូវបុណ្យទាន ទទួលបានប្រាក់ចំណូលក្នុងមួយថ្ងៃក្នុងចន្លោះពី៨០០.០០០៛ ទៅ ១.០០០.០០០៛ (អត្រាប្រាក់ចំណេញ ក្នុងចន្លោះពី៣ទៅ៥%) ប្រាក់ចំណូលដែលទទួលបានពីការធ្វើអាជីវកម្ម គ្រួសារខ្ញុំពង្រីកការប្រមូលទិញ លក់ មានលក្ខណៈទ្រង់ទ្រាយធំជាងមុន។ មកដល់ពេលនេះឥវ៉ាន់ខ្ញុំលក់គិតជាទឹកប្រាក់មានតម្លៃចំនួន៣.៥០០.០០០៛។

បងស្រីបានបន្តទៀតថា ប្រាក់ចំណូលបានមកទាំងនេះខ្ញុំបានប្រើប្រាស់ទៅលើការសន្សំប្រាក់ដើម្បីផ្លាស់ប្តូររៀងរាល់សប្តាហ៍ សន្សំក្នុងគ្រួសារដើម្បីសងបំណុលចាស់បានចំនួន១.០០០.០០០៛ ចាក់ដីជុំវិញផ្ទះចំនួន ២៨០ឡានដែលចំណាយថវិការអស់១.៧៥០.០០០៛ ទិញបង្គោលរបង៥០.០០០៛ ជួសជុលផ្ទះសម្រាប់ជា



ជម្រកក្នុងគ្រួសារបានសមរម្យ និងចូលរួមវិភាគទានថវិកាសម្រាប់អភិវឌ្ឍន៍ក្នុងសហគមន៍ មិនតែប៉ុណ្ណោះគ្រួសារខ្ញុំបានបង្វិលថវិកាត្រឡប់ចូលគម្រោងចំនួន ៣០០ដុល្លារ សម្រាប់បន្តទៅសមាជិកថ្មីទៀត ទោះជាខ្ញុំដល់ពេលដែលត្រូវសងត្រឡប់ថវិកាចូលគម្រោងវិញក៏ដោយ ក៏គ្រួសារខ្ញុំនៅបន្តការប្រមូលទិញលក់ផលិតបន្តទៀត ព្រោះការទិញលក់នេះធ្វើជីវភាពគ្រួសារខ្ញុំមានមុខរបរច្បាស់លាស់ មានប្រាក់ចំណូលជាប់ជាប្រចាំ។

បើក្រលេកមកមើលអារម្មណ៏ក្នុងគ្រួសាររបស់គាត់បច្ចុប្បន្នខុសប្លែកពីអារម្មណ៍ចាស់កាលពីមិនទាន់ចូលគម្រោង គ្រួសារគាត់មានការសប្បាយរីករាយព្រមទាំងពេញចិត្ត ព្រោះគម្រោងបានជួយឲ្យគ្រួសារគាត់មានចំណេះដឹង មានវិធីសាស្រ្តក្នុងការកត់ត្រាតាមដានចំណូលចំណាយ ប្រមូលទិញផលិតផល ជាពិសេសមានដើមទុនពង្រីកមុខរបរបន្ថែម ដែលធ្វើឲ្យគ្រួសារគាត់មានការផ្លាស់ប្តូរទាំងជីវភាពរស់នៅ ឥរិយាបថ និងចេះកែច្នៃផលិតផលដែលជាតម្រូវការទីផ្សារ និងតម្រូវការសហគមន៍ ការផ្លាស់ប្តូរការគិត គំនិតវិជ្ជមាន ធ្វើឲ្យគ្រួសារគាត់មានការផ្លាស់ប្តូរខ្លាំង។ គ្រួសារខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការEPDO និងម្ចាស់ជំនួយ ACR/ Caritas Australia ដែលបានជួយបណ្តុះគំនិត ផ្តល់បច្ចេកទេស និងវិនយោគថវិកាដើម្បីឲ្យគ្រួសារខ្ញុំមានលទ្ធភាពក្នុងការ បង្កើនមុខរបររកប្រាក់ចំណូល ធ្វើឲ្យគ្រួសារខ្ញុំមានការផ្លាស់ប្រែ មានភាពរីកចម្រើនគួជាទីពេញចិត្ត។



# កម្រោងរួមគ្នាលើកកំពស់ផលិតកម្មសត្វ ដើម្បីនិរន្តរភាពជីវភាព និងបរិស្ថានសហគមន៍

# Civil Society, Authorities and Markets for Sustainable Community Animal Production, Livelihoods and Environment (CAM4SCALE)

**គាំទ្រថវិកាដោយ**

## I. សេចក្តីផ្តើម

### I.1. ការបរិយាយអំពីគំរោង

ដោយមានកិច្ចសហការជាមួយអង្គការ ភីព ផល អ៊ីន នីត (ភីន) ក្នុងការអនុវត្តន៍គម្រោង **រួមគ្នាលើកកំពស់ផលិតកម្មសត្វ ដើម្បីនិរន្តរភាពជីវភាព និងបរិស្ថានសហគមន៍** អង្គការអភិវឌ្ឍន៍ និង ការពារបរិស្ថាន (EPDO) ដែលបានកំពុងអនុវត្តន៍គំរោង ដែលមានភូមិគោលដៅចំនួន ២៨ ភូមិ នៅក្នុងឃុំស្រែស្តុក ឃុំកញ្ជរ ឃុំស្បា ឃុំកណ្តៀង និងឃុំស្វាយលួង នៃស្រុកកណ្តៀង ខេត្តពោធិ៍សាត់ និង ២៨ភូមិគោលដៅ នៅក្នុងឃុំគារ ឃុំរបស់មង្គល ឃុំមោង ឃុំតាលាស់ និងឃុំជ្រៃ នៃស្រុកមោងឬស្សី ខេត្តបាត់ដំបង។ គំរោងនេះ បានចាប់ផ្តើមអនុវត្តន៍រយះពេល ២៣ខែ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៦ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។ គម្រោង CAM4SCALE នេះបានទទួលមូលនិធិពីសហភាពអ៊ឺរ៉ុប (EU) តាមរយៈនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយថវិកាសរុបរបស់គម្រោងនេះ គឺមានប្រមាណ ២០៦,០៣៣ដុល្លារអាមេរិក។

### I. 2. គោលបំណងគំរោង

**គោលបំណងរួម** ៖ ដើម្បីកែលំអរជីវភាពរបស់កសិករក្រីក្រប្រកបដោយនិរន្តរភាពនៅក្នុងខេត្តចំនួន ២ ក្នុងប្រទេសកម្ពុជានៅពាក់កណ្តាលឆ្នាំ ២០១៨ តាមរយៈកិច្ចសហប្រតិបត្តិការល្អរវាងអ្នកផលិតសត្វ អ្នកផ្តល់សេវាកម្ម និងអ្នកទីផ្សារ ។

**គោលបំណងជាក់លាក់នៃគំរោង** ៖ គ្រួសារក្រីក្រដែលជាអ្នកចិញ្ចឹមសត្វ ផ្នែកឯកជន អង្គការសង្គមស៊ីវិល អាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ សហការដើម្បីពង្រឹងផ្នែកចិញ្ចឹមសត្វរបស់ប្រទេសកម្ពុជា ។

## I. ៣. ក្រុមគោលដៅ និងភាគីពាក់ព័ន្ធ

| ក្រុមគោលដៅ | ភាគីពាក់ព័ន្ធសំខាន់ៗ |
|---|---|
| ក្រុមផលិតកម្ម និងទីផ្សារសត្វ | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ និងបាត់ដំបង |
| កសិករក្រីក្រ និងមធ្យម | ការិយាល័យផលិតកម្ម និងបសុព្យាបាល |
| ស្ត្រី និងយុវជន | មន្ត្រីពេទ្យសត្វស្រុក និងពេទ្យសត្វឃុំ |
| ភ្នាក់ងារសុខភាពសត្វភូមិ | ក្រុមប្រឹក្សាឃុំ និងប្រធានភូមិ |
| សហគ្រិនផលិតកូនមាន់ស្រែ | ក្រុមហ៊ុនមេឌីវ៉េត |
| សហគមន៍កសិកម្ម | ក្រុមហ៊ុនមាន់ស្រែ |
| ក្រុមបង្វិលសត្វ (ធនាគារគោ) | ក្រុមហ៊ុនមាន់ស្រែ |

# II. លទ្ធផលសំរេចបានរបស់គំរោង

## II.១. ការពង្រឹងសមត្ថភាពក្រុមផលិតកម្ម និងទីផ្សារសត្វ










**កសិករ ៣៣១៥ នាក់** រួមមានស្ត្រី ២០១៥៥ និង យុវជន ៣១៨ នាក់បានចូលរួមកម្មវិធីផ្សព្វផ្សាយសេវាកម្មភ្នាក់ងារសុខភាពសត្វភូមិ ក្នុងគោលបំណងដើម្បីយល់ច្បាស់អំពីសេវាកម្មភ្នាក់ងារសុខភាពសត្វភូមិ និងស្វែងយល់អំពីគំរោងដែលត្រូវអនុវត្តន៍ ។

បន្ទាប់ពីកសិករបានចូលរួមកម្មវិធីផ្សព្វផ្សារ អង្គការអ៊ីបដូរបានរៀបកិច្ចប្រជុំថ្នាក់ភូមិដើម្បីជ្រើសរើសកសិករចូលរួមក្នុងគំរោង ក្នុងនោះដែរ**កសិករចិញ្ចឹមសត្វ ២២៦៦នាក់** បានចុះឈ្មោះជាសមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ និង បង្កើតបាន ២១៦ក្រុម ។ ដើម្បីពង្រឹងសមត្ថភាព និងផ្លាស់ប្តូរទំលាប់ពីការចិញ្ចឹមមាន់តាមទំលាប់ទៅជាចិញ្ចឹមតាមបច្ចេកទេស **សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ១៥២៨នាក់** រួមមាន ស្ត្រី ១០៤៨ យុវជន១០៦ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់តាមបច្ចេកទេស ។

ដើម្បីចិញ្ចឹមមាន់ទទួលបានជោគជ័យ **សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វចំនួន ១៨៥៨នាក់ និងស្ត្រី ១១៦៣នាក់** ទទួលបានវគ្គបណ្តុះបណ្តាលពីការធ្វើផែនការអាជីវកម្មដែលពាក់ព័ន្ធការចិញ្ចឹមមាន់ ក្នុងនោះដែរកសិករចំនួន ៥៦០នាក់បានបញ្ចប់ការសាងសង់ទ្រុងទៅតាមផែនការ ។



ដើម្បីប្រដដថាសមាជិកបានយកបច្ចេកទេសទៅអនុវត្តន៍ ភ្នាក់ងារសុខភាពសត្វភូមិ និងបុគ្គលិកគំរោងអង្គការអ៊ីបដូរ បានបង្វឹកបច្ចេកទេសចិញ្ចឹមមាន់ដល់**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ចំនួន ១៥២៨នាក់** ។



**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ៤៥នាក់** បានចូលរួម លក់មាន់ជាក្រុម និងបានបង្កើតកន្លែងលក់មាន់រួម មាន១៨ភូមិ ក្នុងគោលបំណងដើម្បីអោយកសិករទទួលបានតំលៃសមរម្យ និងធានាបាននូវលំនឹងទីផ្សារលើតំលៃមាន់ ។

**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ១៤៥នាក់** បានចូលរួមចាក់វ៉ាក់សាំងរួម ជាលទ្ធផលមាន់ចំនួន ១៨៧៥ក្បាលបានចាក់វ៉ាក់សាំងញូវកាស អ៊ុត និងអាសន្នរោគ



**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ៥៦នាក់** បានជ្រើសរើស ជាកសិករគំរូលើការចិញ្ចឹមមាន់ និងជាកន្លែងរៀន សូត្រសំរាប់កសិករក្នុងភូមិ និងក្រៅភូមិគោលដៅ



**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ១២៤៥នាក់ និងស្ត្រី ៨៧៦នាក់** ទទួលបានវគ្គបណ្តុះបណ្តាលពីការគ្រប់គ្រងហិរញ្ញវត្ថុលក្ខណៈគ្រួសារ ។



**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ១៥២៨នាក់** បានចូលរួមទស្សនៈកិច្ចសិក្សាមើលកសិករគំរូអំពីការចិញ្ចឹមមាន់ក្នុងភូមិ

**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ចំនួន ១០៥នាក់** បានចូលរួមបង្កើតក្រុមសន្សំចំនួន ១៦ក្រុម ដែលមានថវិកាសរុប ១០,៥០០,០០០ រៀល



**សមាជិកក្រុមផលិតកម្ម និងទីផ្សារសត្វ ចំនួន ៥៦០នាក់** បានទទួលសម្ភារៈ(ស្នូកទឹក និងសំណាញ់) ដើម្បីពង្រឹងការចិញ្ចឹមមាន់ទៅតាមលក្ខណៈបច្ចេកទេស

## II.២. ការពង្រឹងសមត្ថភាពភ្នាក់ងារសុខភាពសត្វភូមិ



**ភ្នាក់ងារសុខភាពសត្វភូមិ ៥៦នាក់** ទទួលបានវគ្គបណ្តុះបណ្តាលគ្រូបង្គោលពី ការចិញ្ចឹមមាន់តាមបច្ចេកទេស ការធ្វើផែនការអាជីវកម្ម បច្ចេកទេសព្យាបាលជ្រូក គោក្របី ជំនាញទំនាក់ទំនង និងធ្វើបទបង្ហាញ ទស្សនៈទានក្រុមសន្សំ និងការកត់ត្រាសេវាកម្មអតិថិជន និងជំនួញទីផ្សារ



**ភ្នាក់ងារសុខភាពសត្វភូមិ ៥៦នាក់** ទទួលបានសំភារៈពេទ្យសត្វ (ការបូប ធុងដាក់វ៉ាក់សាំង ប្រដាប់ស្ទង់កំដៅ) និងថវិកាចំនួន ៦០.០០០រៀលដើម្បីសាងសង់កន្លែងស្តុកកាក់សំណល់



**ភ្នាក់ងារសុខភាពសត្វភូមិ** បានបណ្តុះបណ្តាលបច្ចេទេសចិញ្ចឹមមាន់ ជីវសុវត្ថិភាព សារៈប្រយោជន៍របស់វ៉ាក់សាំង និង បង្វឹកដល់សមាជិកក្រុមកសិករចិញ្ចឹមសត្វ

**ភ្នាក់ងារសុខភាពសត្វភូមិ** បានផ្តល់សេវាចាក់វ៉ាក់សាំងការប្រឹក្សាយោបល់លើបច្ចេកទេស ចិញ្ចឹម មាន់ ជ្រូក គោក្របី និងការព្យាបាល ដល់សមាជិក ក្រុមកសិករចិញ្ចឹមសត្វ និង កសិករក្រៅគោលដៅ



**ភ្នាក់ងារសុខភាពសត្វភូមិ ៥៦នាក់** បានចូលរួមទស្សនៈកិច្ចសិក្សាពីការចិញ្ចឹមមាន់នៅ ខេត្តបាត់ដំបង ដើម្បីមើលការចិញ្ចឹមមាន់គំរូ និងចុះអនុវត្តន៍ជាក់ស្តែងលើការប្រើប្រាស់វ៉ាក់សាំង ។

## II.៣ ក្រុមប្រឹក្សាឃុំគោលដៅ និងការិយាល័យផលិតកម្ម និងបសុព្យាបាល



**ភ្នាក់ងារសុខភាពសត្វភូមិ សមាជិកក្រុម និង កសិករចំនួន៣៤៨**ចូលរួមវេទិការពិគ្រោះយោបល់ថ្នាក់ឃុំស្តីពីផលិតកម្មសត្វ (ឃុំស្វាយលួង កណ្តៀង កញ្ជរ ស្រែស្តុក នៃស្រុកណ្តៀង និងឃុំគា មោង របស់មង្គលជ្រៃ និងឃុំតាលាស់នៃស្រុកមោងឬស្សី)



**តំណាងសមាជិកក្រុម ភ្នាក់ងារសុខភាពសត្វភូមិ និងភាគីពាក់ព័ន្ធសំខាន់ៗ ១១៨ នាក់** ចូលរួមវេទិការកសិករចិញ្ចឹមសត្វថ្នាក់ស្រុកស្តីពីផលិត កម្មសត្វ



**ពេទ្យសត្វស្រុកស្រុកកណ្តៀង និងមន្ត្រីសំរបសំរួលអង្គការអុីបដូវ**ប្រចាំខែចូលរួមការប្រជុំជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលដើម្បីបង្ហាញពីរបាយការណ៍រីកចំរើន បញ្ហាជួបប្រទះ និងផែនការបន្ត



**អង្គការអុីបដូវ សហការជាមួយការិយាល័យផលិត និងបសុព្យាបាល** បានរៀបចំសិក្ខាសាលាស្តីពីការជួបគ្នារវាងឈ្មួញ និងកសិករចិញ្ចឹមសត្វ

## III. ការផ្លាស់ប្តូរសំខាន់ៗ

### ១. សមាជិកក្រុមចិញ្ចឹមសត្វទទួលស្គាល់សេវាកម្មពេទ្យសត្វ



លោក ឡុង រ៉ូយ ពេទ្យសត្វភូមិប្រឡាយស្តៅ កំពុងចាក់វ៉ាក់សាំងដល់សមាជិកក្រុមចិញ្ចឹមសត្វ

មុនពេលគំរោងចាប់ផ្តើម មានកសិករមួយចំនួនបានប្រើប្រាស់សេវាកម្មពេទ្យសត្វលើការព្យាបាលជ្រូក គោក្របីតែប៉ុណ្ណោះ ចំនែកសេវាកម្មផ្នែកចាក់វ៉ាក់សាំងមាន់ ពួកគាត់មិនដែលទាក់ទងពេទ្យសត្វភូមិក្នុងការផ្តល់សេវាកម្មឡើយប៉ុន្តែ នៅពេលគំរោងបានអនុវត្តន៍ ក្នុងចំណោមសមាជិកក្រុមចិញ្ចឹមសត្វ ២២៦នាក់ ***៣២ភាគរយ*** នៃសមាជិកក្រុមបានប្រើប្រាស់សេវាកម្មចាក់វ៉ាក់សាំង ។ បន្ថែមពីនេះទៀត សមាជិកក្រុមចិញ្ចឹមសត្វបានយល់ច្បាស់ អំពីប្រភេទវ៉ាក់សាំង និងពេលវេលាដែលត្រូវចាក់វ៉ាក់សាំងដល់មាន់ ។ លោកឡុង រ៉ូយ ជាពេទ្យសត្វភូមិប្រឡាយស្តៅ បានលើកឡើងថា "***ពីមុនខ្ញុំមិនដែលទទួលបានប្រាក់ចំណូលពីសេវាកម្មចាក់វ៉ាក់សាំងមាន់ឡើយ ប៉ុន្តែឥលូវ កសិករនៅក្នុងភូមិរបស់ខ្ញុំបានទាក់ទងខ្ញុំដើម្បី ផ្តល់សេវាកម្មចាក់វ៉ាក់សាំងមាន់***" ។



លោក ណក ស្មាន ពេទ្យសត្វភូមិកណ្តាលកំពុងផ្តល់វគ្គបច្ចេកទេសចិញ្ចឹមមាន់ដល់សមាជិកក្រុម

ជាធម្មតា ភាគច្រើននៃវគ្គបណ្តុះបណ្តាលចិញ្ចឹមសត្វ តែងតែបណ្តុះបណ្តាលដោយគ្រូឧទេសមកពីស្ថាប័ន និង អង្គការផ្សេងៗដើម្បីបង្ហាត់បង្រៀនដល់កសិករ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលក្រោយពេលវគ្គ ពុំសូវមានប្រសិទ្ធភាពឡើយពីព្រោះកសិករមិនទទួលបានការបង្វិកបន្ថែម និងតាមដានពីគ្រូបណ្តុះបណ្តាល ។ ដោយមើលឃើញចំនុចនេះ អង្គការអ៊ីបដូរ បានពង្រឹងសមត្ថភាពដល់ពេទ្យសត្វភូមិទៅលើជំនាញគ្រូបង្គោល និងបច្ចេកទេសផ្សេងទៀតដើម្បីជានាក្នុងការ ផ្តល់វគ្គបណ្តុះបណ្តាលដែលមានគុណភាពដល់សមាជិកក្រុមចិញ្ចឹមសត្វ យើងអាចមើលឃើញថាកសិករទូទៅ និងសមាជិកក្រុមចិញ្ចឹមសត្វបានទទួលស្គាល់ពីសមត្ថភាពរបស់ពេទ្យសត្វភូមិបន្ទាប់ពីពួកគាត់បានចូលរួមវគ្គបណ្តុះបណ្តាល ជាពិសេសកសិករភាគច្រើនបាន អនុវត្តន៍ទៅតាមបច្ចេកទេសបន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលនិង ការបង្វិកបន្ថែមព្រមទាំងការតាមដានពីពេទ្យសត្វភូមិ ។ បើយោងតាមទិន្នន័យបង្ហាញថា ៦០ភាគរយនៃចំនួនសមាជិកក្រុម ២២៦នាក់ បានចូលរួម វគ្គបណ្តុះបណ្តាលដែលរៀបចំដោយ ពេទ្យសត្វភូមិ និង ៦០ភាគរយនៃសមាជិកក្រុមសរុបបានទទួល ការប្រឹក្សាយោបល់ពីពេទ្យសត្វភូមិទាក់ទងនឹងការចិញ្ចឹមសត្វ លោក ណក ស្មាន ពេទ្យសត្វភូមិកណ្តាលបាន លើកឡើងថា "***ខ្ញុំមិនដែលរំពឹងថា ខ្ញុំអាចមានសមត្ថភាពក្នុងការផ្តល់វគ្គបណ្តុះ បណ្តាល បច្ចេកទេស លើកា ចិញ្ចឹមមាន់ ប៉ុន្តែឥលូវខ្ញុំមានសមត្ថភាពធ្វើបទបង្ហាញ និងបណ្តុះបណ្តាលយ៉ាងមានភាពជឿជាក់ ដល់ កសិករ***" លោកបានបន្ថែមទៀតថា " **បើសិនពុំមានការគាំទ្រពីអង្គការអ៊ីបដូរ ខ្ញុំមិនអាចមាន សមត្ថភាពដូចពេលនេះទេ**"

### ២. ជំនាញបច្ចេកទេសរបស់សមាជិកក្រុមផលិតកម្ម និងទីផ្សារ



អ្នកស្រី ស៊ីន ប៊ុនធន គឺកំពុងផ្ដល់ចំណីមាន់ និងកូនមាន់

ជាទំលាប់កសិករចិញ្ចឹមមាន់មួយចំនួនចិញ្ចឹមមាន់មិនអនុវត្តន៍តាម បច្ចេកទេសទេ ពួកគាត់ចិញ្ចឹមមាន់ដោយមិនមានទ្រុងមាន់ដេក បែងចែកប្លុក សៃ្ប ព័ទ្ធជុំវិញ ការប្រើការបោរស ការផ្សំចំណី និងមិនមានផែនការចិញ្ចឹមមាន់ ។ ប៉ុន្តែក្រោយពីគំរោងចាប់ផ្តើម អនុវត្តន៍សមាជិកក្រុមបានផ្លាស់ប្តូរពីការចិញ្ចឹមតាមទំលាប់ទៅតាមលក្ខណៈបច្ចេទេស ។ អ្នកស្រី ស៊ីន ប៊ុនធនជាកសិករចិញ្ចឹមមាន់គំរូនៅ ភូមិប្រឡាយស្តៅបាននិយាយថា " *ចាប់តាំងពី ខ្ញុំបានក្លាយជាសមាជិកក្រុមចិញ្ចឹមសត្វ ខ្ញុំបានទទួល វគ្គបណ្តុះបណ្តាលដូចជា ការចិញ្ចឹមមាន់ ជីវសុវត្តិភាព ការផ្សំចំណី និងផែនការ អាជីវកម្មជាដើម* " អ្នកស្រីបានបន្ថែមទៀតថា "*ឥលូវខ្ញុំយល់ច្បាស់អំពីការចិញ្ចឹមមាន់ដ៏មានប្រសិទ្ធិភាព និងជោគជ័យ ពីមុនខ្ញុំមិនដឹងពីរបៀបផ្សំចំណី ការថែទាំ មិនដឹងការប្រើការបោរសដើម្បីការពារជំងឺផ្លូង មិនសាងសងទ្រុងមាន់ដេក ប្លុក និងមិនព័ទ្ធសំណាញ់ជុំវិញ ប៉ុន្តែក្រោយពេលចិញ្ចឹមមាន់តាមលក្ខណៈបច្ចេកទេសដោយផ្អែកលើផែនការមាន់របស់ខ្ញុំ ឥលូវ មាន់របស់ខ្ញុំគឺកើនពីដល់ ១៥០ក្បាល ដូច្នោះខ្ញុំអាចរកប្រាក់ចំណូលពី ៤០០,០០០ ទៅ ៦០០,០០០ រៀលជារៀងរាល់ខែ* " ។

### ៣. ការចិញ្ចឹមមាន់គំរូរបស់ភ្នាក់ងារសុខភាពសត្វភូមិ



លោក មាស សម្បត្តិ ពេទ្យសត្វភូមិព្រៃព្រំមួយ កំពុងផ្តល់ចំណីអោយមាន់

ផ្អែកលើការសិក្សារបស់ក្រុមការងារអង្គការអ៊ីបដូរ បានបង្ហាញថាទ្រុងមាន់របស់ពេទ្យសត្វភូមិនិមួយៗគឺមានសភាពចាស់ទ្រុតទ្រោម និង ចិញ្ចឹមមាន់ដោយមិនមានទ្រុងកូនមាន់ ប្លុក មិនមានសំណាញ់ព័ទ្ធជុំវិញ ដោយមើលឃើញដូចនេះ អង្គការអ៊ីបដូរបានផ្តល់នូវទុនខ្នាតតូច និងបច្ចេកទេសចិញ្ចឹមមាន់ដើម្បីធ្វើអោយ ប្រសើរឡើងនូវការសាងសង់ទ្រុងមាន់ ប្លុក ទ្រុងកូនមាន់ និងសំណាញ់ព័ទ្ធជុំវិញទ្រុង។ រហូតមកដល់ពេលនេះ មានពេទ្យសត្វចំនួន **៤២នាក់**បានក្លាយជាពេទ្យសត្វភូមិគំរូលើការចិញ្ចឹមមាន់ និងក្លាយជាកន្លែងបង្ហាញសំរាប់សមាជិកក្រុមចិញ្ចឹមសត្វ និងកសិករទូទៅធ្វើទស្សនៈកិច្ច និងយកគំរូតាម ។

## IV. មេរៀនជាបទពិសោធន៍

- ការផ្តល់វគ្គបណ្តុះបណ្តាលជំនាញធ្វើផែនការជំនួញ និងបង្កើតផែនការជំនួញលើការ ចិញ្ចឹមមាន់វាអាចជួយសមាជិកក្រុមមានផែនការច្បាស់លាស់ និងទទួលបាននូវជោគជ័យស្ទើរតែ ៨០ ភាគ ប្រសិនបើពួកគាត់យកផែនការនោះទៅអនុវត្តន៍ ថែមទាំងជួយផ្លាស់ប្តូរពីទំលាប់មិនល្អ ទៅទំលាប់ល្អលើការចិញ្ចឹមមាន់ ។
- ដើម្បីធ្វើអោយការបណ្តុះបណ្តាលដល់សមាជិកក្រុមកាន់តែមានប្រសិទ្ធិភាព គ្រូបណ្តុះបណ្តាលគួរប្រើរូបភាពអោយច្រើនជាងទ្រឹស្តី ជាពិសេសក្រោយពេលវគ្គបណ្តុះបណ្តាលគ្រូបណ្តុះបណ្តាល

គួរដឹកនាំសមាជិកក្រុមធ្វើទស្សនៈកិច្ចលើការចិញ្ចឹមមាន់គំរូ និងបង្កើតផែនការបន្តជាមួយកសិករ ។

- ការរៀបចំការប្រជុំប្រចាំខែជាមួយពេទ្យសត្វភូមិអាចផ្តល់ព័ត៌មានថ្មីស្តីអំពីការផ្ទុះជំងឺសត្វ ការចែករំលែកមេរៀនជាបទពិសោធន៍អំពីការចិញ្ចឹមសត្វរវាងពេទ្យសត្វភូមិ និងពេទ្យសត្វភូមិ និងទទួលបាន ទិន្នន័យចំណូលជាក់ស្តែងពីពួកគាត់ ។
- ការធ្វើផែនការសកម្មភាពជាមួយសមាជិកក្រុមកសិករបន្ទាប់ពីវគ្គបណ្តុះបណ្តាលនៃការចិញ្ចឹមមាន់ អាចធ្វើអោយពេទ្យសត្វភូមិងាយស្រួលតាមដាន និងមានផែនការអាចជួយរំលឹកសមាជិកក្រុមលើសកម្មភាពជាក់ស្តែងដែលពួកគាត់ត្រូវធ្វើបន្ទាប់ពីវគ្គ ។
- ការប្រើប្រាស់ខិតប័ណ្ណចិញ្ចឹមមាន់អំឡុងពេលវគ្គបណ្តុះបណ្តាលអាចជាការណែនាំមួយដ៏ល្អ និងឯកសារសំរាប់អ្នកចូលរួមអនុវត្តន៍ក្រោយពេលវគ្គបណ្តុះបណ្តាល ពីព្រោះ ខិតប័ណ្ណនេះបានសង្ខេប និង បង្ហាញពីវិធីសាស្រ្តងាយស្រួលក្នុងការចិញ្ចឹមមាន់អោយមានប្រសិទ្ធិភាព ។
- ការតាមដាន និងការធ្វើទស្សនៈកិច្ចការចិញ្ចឹមមាន់ និងទ្រុងមាន់របស់សមាជិកក្រុមជាទៀងទាត់នឹងជួយជំរុញ និងលើកទឹកចិត្តសមាជិកបណ្តាញអោយអនុវត្តន៍ផែនការសកម្មភាពប្រកបដោយប្រសិទ្ធិភាព ។
- ការង្កើតអោយមានការចិញ្ចឹមមាន់តាមបែបគំរូរបស់ពេទ្យសត្វភូមិ នឹងត្រូវបានបង្ហាញអោយសមាជិកក្រុមអនុវត្តន៍តាម និងយកជាគំរូ ។
- ការបង្កើតក្រុមសន្សំនៅក្នុងសមាគមពេទ្យសត្វនឹងអាចជួយជំរុញពេទ្យសត្វភូមិទាំងអស់មកចូលរួម ប្រជុំប្រចាំខែជាទៀងទាត់ ។ បន្ថែមពីនេះទៀត ការប្រជុំប្រចាំខែជាមួយពេទ្យសត្វភូមិនឹងជួយបង្វឹក ពួកគាត់អោយចេះធ្វើការរួមគ្នានឹងអាចក្លាយជាភាពជាអ្នកដឹកនាំមួយដ៏ល្អក្នុងចំណោមពេទ្យសត្វភូមិ ជាពិសេសវាជាគំរូសំរាប់ក្រុមកសិករចិញ្ចឹមមាន់ អនុវត្តន៍តាម ។
- ការធ្វើផែនការសកម្មភាពរវាងពេទ្យសត្វភូមិ និងសមាជិកក្រុមកសិករចិញ្ចឹមសត្វអំឡុងពេលផ្តល់ទុនខ្នាតតូច បានជួយជំរុញសមាជិកក្រុមធ្វើតាមផែនការជំនួញ និងអាចផ្តល់ឱកាស និងផ្តល់សិទ្ធិដល់ពេទ្យសត្វភូមិក្នុងការតាមដានសមាជិកក្រុម ។
- ខិតប័ណ្ណនៃលទ្ធផលខ្សែសង្វាក់ផលិតកម្មមាន់អាចអនុញ្ញាតអោយកសិករតថ្លៃតំលៃការលក់មាន់ជា មួយឈ្មួញកណ្តាល មុនពេលពួកគាត់សំរេចចិត្តលក់មាន់ ជាពិសេស លទ្ធផលនៃខ្សែសង្វាក់ផលិត កម្មមាន់បានបង្ហាញសមាជិកក្រុមកសិករចិញ្ចឹមសត្វ និងកសិករទូទៅអោយដឹងពីរដូវលក់មាន់បានតម្លៃខ្ពស់ និងទាប ។
- ការរៀបចំសិក្ខាសាលាផ្តួចផ្តើមគំរោងបានជួយអោយពេទ្យសត្វភូមិថ្មី និងអាជ្ញាធរដែនដីយល់ច្បាស់ អំពីគំរោង និងទាក់ទាញចំណាប់អារម្មណ៍អោយពួកគាត់មុនពេលចូលរួមអនុវត្តន៍គំរោង ។

## V. អនុសាសន៍

- កិច្ចប្រជុំរវាងបុគ្គលិកគំរោង និងពេទ្យសត្វភូមិគួររៀបចំជារៀងរាល់ខែដើម្បីទទួលបានព័ត៌មានអំពី ស្ថានភាពសត្វ និងជំងឺកើតឡើងថ្មី ។
- ដើម្បីផ្សព្វផ្សាយកេរ្តិ៍ឈ្មោះម្ចាស់ជំនួយ គំរោងគួរតែផលិតផ្លាកផ្សព្វផ្សាយអោយបានច្រើនហើយបិទនៅថ្នាក់ឃុំ និងថ្នាក់ស្រុក ។

- ដើម្បីធ្វើអោយប្រកដថាពេទ្យសត្វភូមិអនុវត្តន៏ការសាងសង់ទ្រុងមាន់តាមលក្ខណៈបច្ចេកទេស មន្ត្រីសំរបសំរួលគំរោង និងបុគ្គលិកគំរោងគួររៀបចំធ្វើផែនការជាក់លាក់ជាមួយពេទ្យសត្វភូមិ ។
- គំរោងគួររៀបចំករណីសិក្សានៃការអនុវត្តន៍ល្អៗក្នុងការចិញ្ចឹមសត្វ និងផ្សព្វផ្សាយពត៌មាននេះដល់ សមាជិកបណ្តាញ និងកសិករចិញ្ចឹមសត្វទាំងអស់នៅតាមភូមិគោលដៅនិមួយៗ ។
- គំរោងគួររៀបចំផែនការអោយមានប្រសិទ្ធិភាពក្នុងការបង្កើតក្រុមផលិតយ៉ាងហោចណាស់មួយក្រុម ក្នុងមួយភូមិ បន្ទាប់មកបណ្តុះបណ្តាលក្រុមផលិតនិមួយៗអំពីយុទ្ធសាស្រ្តទីផ្សារ និងខ្សែសង្វាក់ ផលិតកម្ម ។
- គំរោងគួរបង្កើតសមាគមពេទ្យសត្វភូមិថ្មី និងពង្រឹងសមាគមពេទ្យសត្វភូមិដែលមានស្រាប់អោយបានឆាប់តាមដែលអាចធ្វើទៅបាននៅក្នុងតំបន់គោលដៅ ពីព្រោះសមាគមពេទ្យសត្វអាចជួយប្រមូលផ្តុំ និងធ្វើអោយពេទ្យសត្វភូមិធ្វើការរួមគ្នាក្នុងការជួយបង្វឹកនិងបណ្តុះបណ្តាលដល់សមាជិក ក្រុមកសិករចិញ្ចឹមសត្វ ។
- ដើម្បីធ្វើអោយសមាជិកក្រុមអនុវត្តន៍ល្អបន្ទាប់ពីការផ្តល់ទុនខ្នាតតូច គំរោងគួររៀបចំទស្សនៈកិច្ចសិក្សា និងដឹកនាំតំណាងសមាជិកក្រុមធ្វើទស្សនៈកិច្ចការចិញ្ចឹមមាន់គំរូទាំងក្នុង និងក្រៅខេត្ត បន្ទាប់មកពួកគេអាចផ្សព្វផ្សាយចំនេះដឹងនេះដល់សមាជិកក្រុម ផ្សេងៗទៀត ។

## VI. គំរោងថវិកាប្រចាំឆ្នាំ ២០១៧

| ល.រ | ឈ្មោះគំរោង | ម្ចាស់ជំនួយ | ថវិកាសរុប (ដុល្លារ) |
|---|---|---|---|
| ១ | គម្រោងរួមគ្នាលើកកំពស់ផលិតកម្មសត្វ ដើម្បីនិរន្តរភាពជីវភាព និងបរិស្ថានសហគមន៍ | EU/GDAHP | ១៤៩,១៤៦.៦៥ |
| ២ | គម្រោង សន្តិភាព និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព សម្រាប់ទាំងអស់គ្នា | ACR/CA | ២៨,០១៤.៧៤ |
| | **សរុប** | | **១៧៧,១៦១.៤០** |